បណ្ណាល័យ
ក.ជ.អ.ប

# រាជរដ្ឋាភិបាលកម្ពុជា

## សុន្ទរកថា

របស់សម្តេច ហ៊ុន សែន

នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

ស្តីពី

## «យុទ្ធសាស្ត្រចតុកោណ»

***ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព នៅកម្ពុជា***

ថ្លែងនៅក្នុងអង្គប្រជុំគណៈរដ្ឋមន្ត្រី លើកទីមួយ

សំរាប់នីតិកាលទី ៣ នៃរដ្ឋសភា

នៅទីស្តីការគណៈរដ្ឋមន្ត្រី

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៤

បោះពុម្ពដោយទីស្តីការគណៈរដ្ឋមន្ត្រី

# សុន្ទរកថា

## របស់សម្តេច ហ៊ុន សែន

## នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

## ស្តីពី

# «យុទ្ធសាស្ត្រចតុកោណ»

***ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព នៅកម្ពុជា***

**ថ្លែងនៅក្នុងអង្គប្រជុំគណៈរដ្ឋមន្ត្រី លើកទីមួយ**

**សំរាប់នីតិកាលទី ៣ នៃរដ្ឋសភា**

**នៅទីស្តីការគណៈរដ្ឋមន្ត្រី**

**រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៤**

352.34
STR..
sh: planning
NCDD Library
001061

*ព្រះអង្គស្តេចក្រុមឃុន ព្រះអង្គម្ចាស់ ព្រះអង្គម្ចាស់ក្សត្រី ឯកឧត្តម លោកជំទាវ- -ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ- - ដែលជាសមាជិក- សមាជិកានៃអង្គគណៈរដ្ឋមន្ត្រីទាំងមូល ជាទីគោរព !*

ថ្ងៃនេះ គឺជាទិវាប្រវត្តិសាស្ត្រដ៏សំខាន់មួយរបស់កម្ពុជា ដែលរាជរដ្ឋាភិបាលកម្ពុជាសំរាប់នីតិកាលទី៣ នៃរដ្ឋសភា បានបើកកិច្ចប្រជុំពេញអង្គរបស់ខ្លួនជាលើកទី១ ។ ក្នុងនាមជាប្រមុខនៃរាជរដ្ឋាភិបាល ទូលបង្គំ ខ្ញុំ សូមសំដែងការស្វាគមន៍យ៉ាងកក់ក្តៅជាទីបំផុត ថ្វាយ និង ជូន ចំពោះព្រះអង្គស្តេចក្រុមឃុន ព្រះអង្គម្ចាស់ ព្រះអង្គម្ចាស់ក្សត្រី ឯកឧត្តម និង លោកជំទាវទាំងអស់ ដែលជាសហការីនៅក្នុងរាជរដ្ឋាភិបាលសំរាប់នីតិកាលទី ៣ នៃរដ្ឋសភា ។

តាមទម្លាប់នៃការអនុវត្តន៍កន្លងមក នៅក្នុងការចាប់ផ្តើមចូលកាន់ការងាររបស់រាជរដ្ឋាភិបាលថ្មី អង្គប្រជុំលើកទី ១ នៃគណៈរដ្ឋមន្ត្រី តែងត្រូវបានប្រើប្រាស់ជាកាលានុវត្តភាព សំរាប់ការគូសរំលេចជូនបងប្អូនជនរួមជាតិកម្ពុជា និងដៃគូអន្តរជាតិទាំងអស់ជ្រាប អំពីអាទិភាពគោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាល សំរាប់នីតិកាលថ្មី និង អំពីការប្តេជ្ញាចិត្តយ៉ាងមោះមុតឥតងាករេរបស់រាជរដ្ឋាភិបាលទាំងមូល ក្នុងការឈានទៅសំរេចឱ្យបានជោគជ័យនូវបណ្តាអាទិភាពទាំងអស់នោះ ដើម្បីបំពេញនូវឧត្តមប្រយោជន៍របស់ប្រទេសជាតិ មាតុភូមិ និង ឆ្លើយតបទៅនឹងសំណូមពរ និង សេចក្តីត្រូវការទាំងឡាយរបស់ប្រជាពលរដ្ឋកម្ពុជា ដែលរាជរដ្ឋាភិបាលបានទទួលតាមរយៈសម្លេងឆ្នោតផ្តល់ការទុកចិត្ត ក្នុងកិច្ចដំណើរការបោះឆ្នោតប្រជាធិបតេយ្យ ដោយសេរី និងយុត្តិធម៌ ។ ដូច្នេះ ទូលបង្គំ ខ្ញុំសូមស្នើថា អង្គប្រជុំ

គណៈរដ្ឋមន្ត្រីរបស់យើងនាថ្ងៃនេះ ត្រូវតែចាប់ផ្តើមបើកឆាកការងាររបស់ខ្លួន ស្របតាមស្មារតីនៃប្រពៃណីដ៏ល្អនេះ ។

ដូចទូលបង្គំ ខ្ញុំ ធ្លាប់បានលើកឡើងជាច្រើនលើកច្រើនសាររួចមកហើយ ទាំងនៅលើវេទិកាជាតិ ទាំងនៅលើវេទិកាអន្តរជាតិ ទូលបង្គំ ខ្ញុំ មានជំនឿដ៏មុតមាំថា កម្ពុជាគ្មានជម្រើសអ្វីផ្សេងឡើយ ក្រៅពីការបន្តជម្រុញអនុវត្តយ៉ាងហ្មឹងម៉ាត់ និង មធ្យ័តបំផុត នូវកម្មវិធីកំណែទម្រង់ទាំងឡាយដែលមានលក្ខណៈកាន់តែទូលំទូលាយឡើង និង កាន់តែស៊ីជម្រៅឡើង ។ កំណែទម្រង់ គឺជាកិច្ចការស្លាប់រស់របស់កម្ពុជា ។ បើយើងរួមគ្នាធ្វើកំណែទម្រង់ នោះទើបយើងសង្ឃឹមថា នឹងអាចរំដោះខ្លួនចេញបានពីវដ្តសង្សារនៃភាពក្រីក្រតោកយ៉ាក ហើយស្តារឡើងវិញបាននូវភាពថ្លៃថ្នូររបស់ប្រជាជាតិមួយ ដែលធ្លាប់តែមានមោទនភាព និង ដែលធ្លាប់ត្រូវបានគេគោរព និង កោតសរសើរ ។ ផ្ទុយទៅវិញ បើយើងគេចវេះកំណែទម្រង់ យើងប្រាកដជានឹងបាត់បង់សំណាង និង កាលានុវត្តភាព ដែលយើងកំពុងក្តាប់ក្នុងដៃនាពេលបច្ចុប្បន្ននេះ ហើយនឹងបន្តស្ថិតក្នុងភាពក្រីក្រពុំរ៉ៃ ជម្លោះ និង អស្ថិរភាព មិនចេះចប់ ។

នៅក្នុងបរិការណ៍នេះ កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលសំរាប់នីតិកាលទី ៣ នៃរដ្ឋសភា ដែលជាចក្ខុវិស័យរួមរបស់ជាតិ និង ជាសេចក្តីប្រកាសអំពីបេសកកម្ម និង ឆន្ទៈរបស់រាជរដ្ឋាភិបាល សំរាប់នីតិកាលទី ៣ នៃរដ្ឋសភា ហើយដែលសំរេចបានមកលើមូលដ្ឋាននៃការឯកភាពមតិគ្នាក្នុងចំណោមដៃគូ ដែលចូលរួមក្នុងរាជរដ្ឋាភិបាលថ្មីនេះ នឹងដើរតួជាក្របខ័ណ្ឌការងារដ៏សំខាន់បំផុតរបស់យើង សំរាប់រយៈពេល ៤ ឆ្នាំទៅមុខទៀត ។

យ៉ាងណាមិញ ទូលបង្គំ ខ្ញុំ យល់ថា ក្នុងការដឹកនាំអនុវត្តកម្មវិធីនយោបាយនេះ រាជរដ្ឋាភិបាលមានសេចក្ដីត្រូវការដ៏ចាំបាច់ក្នុងការធ្វើអាទិភាវូបនីយកម្មបណ្ដាអាទិភាព ដែលយើងបានដាក់ចេញមក ដោយផ្ដោតជាសំខាន់ទៅលើរបៀបវារៈនៃគោលនយោបាយសេដ្ឋកិច្ច និង ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន តាមរយៈការរៀបចំលំអិតបន្ថែមដោយអន្លើ ហើយសម្រិតសម្រាំងសម្រួច និង រំលេច នូវរបៀបវារៈគោលនយោបាយសេដ្ឋកិច្ចរបស់កម្មវិធីនយោបាយនេះ ឱ្យចេញជាកញ្ចប់អាទិភាពទៅតាមបណ្ដាវិស័យសំខាន់ៗនានា ដែលមានលក្ខណៈជាប្រព័ន្ធ ស៊ីសង្វាក់ ប្រទាក់ក្រឡាគ្នា និង យោងគ្នាទៅវិញទៅមក ហើយងាយយល់ និង ងាយគ្រប់គ្រង ។ គឺក្នុងស្មារតីនេះហើយ ដែលខ្ញុំមានបំណងដាក់ជូនអង្គប្រជុំគណៈរដ្ឋមន្ត្រីលើកទី ១ របស់យើងនាថ្ងៃនេះ និង ជូនបងប្អូនជនរួមជាតិ ព្រមទាំងដៃគូអភិវឌ្ឍន៍ទាំងអស់របស់កម្ពុជាជ្រាប អំពី **«យុទ្ធសាស្ត្រចតុកោណ» ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាពនៅកម្ពុជា** ដែលនឹងដើរតួជាឧបករណ៍ដ៏សំខាន់សំរាប់ទ្រទ្រង់ការអនុវត្តន៍ **«កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលសំរាប់នីតិកាលទី ៣ នៃរដ្ឋសភា»** ។

សូមអនុញ្ញាតឱ្យ ទូលបង្គំ ខ្ញុំ ធ្វើការអធិប្បាយអំពីយុទ្ធសាស្ត្រនេះដូចតទៅ៖

# ផ្នែកទី ១

## ខ្លឹមសារនៃយុទ្ធសាស្ត្រចតុកោណ

### ១.១. គោលដៅចំបងរបស់រាជរដ្ឋាភិបាលនីតិកាលទី ៣ នៃរដ្ឋសភា

ប្រជាពលរដ្ឋនៃព្រះរាជាណាចក្រកម្ពុជា បានសំដែងនូវឆន្ទៈជាសមូហភាពរបស់ខ្លួន តាមរយៈការបោះឆ្នោតជាសាកលដែលអ្នកសង្កេតការជាតិ និងអន្តរជាតិ បានវាយតម្លៃថា ជាការបោះឆ្នោតមួយសេរី យុត្តិធម៌ ត្រឹមត្រូវ មានតម្លាភាព និងអាចទទួលយកបាន កាលពីថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៣ ។ រាជរដ្ឋាភិបាលបានឈានចូលកាន់អំណាចក្នុងនីតិកាលទី ៣ នៃរដ្ឋសភាស្របទៅតាមឆន្ទៈរបស់ប្រជារាស្ត្រ ជាមួយនឹងការប្តេជ្ញាចិត្តយ៉ាងពេញទំហឹងចំពោះបុព្វហេតុនៃសុខសន្តិភាព ការបង្រួបបង្រួមជាតិ ស្ថិរភាពសណ្តាប់ធ្នាប់សង្គម ការលើកស្ទួយលទ្ធិប្រជាធិបតេយ្យ ការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស ឯករាជ្យជាតិ អធិបតេយ្យភាព និង កិត្យានុភាពជាតិ បូរណភាពទឹកដី និងការអភិវឌ្ឍន៍ប្រកបដោយចិរភាព ដែលនឹងផ្តល់ជូនដល់ប្រទេសជាតិ និង ប្រជាជនគ្រប់ស្រទាប់ជាន់ថ្នាក់នូវវឌ្ឍនភាព វិបុលភាព ភាពសុខដុមរមនា និង ជីវភាពសមរម្យថ្លៃថ្នូរ ។

នៅក្នុងន័យនេះ ទិសដៅជាសារវន្តរបស់រាជរដ្ឋាភិបាលនៃរដ្ឋសភានីតិកាលទី ៣ គឺកសាងជាជំហានៗនូវសង្គមកម្ពុជាមួយ ដែលមានសុខ-

សន្តិភាព ស្ថិរភាព សណ្តាប់ធ្នាប់សង្គម មានការគោរពយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍ប្រជាធិបតេយ្យ ព្រមទាំងសិទ្ធិ និង សេចក្តីថ្លៃថ្នូរបស់មនុស្ស មានការអភិវឌ្ឍន៍ប្រកបដោយចិរភាព និង សមធម៌ មានកោសិកាផ្សារភ្ជាប់គ្នា មានប្រជាជនប្រកបដោយចំណេះដឹងខ្ពស់ និង វប្បធម៌ជ្រៅជ្រះ មានជីវភាពសមរម្យ និង មានការរស់នៅប្រកបដោយភាពសុខដុមរមនាទាំងនៅក្នុងសង្គមជាតិ ទាំងនៅក្នុងក្រុមគ្រួសារ ។

ក្នុងក្របខ័ណ្ឌនេះ រាជរដ្ឋាភិបាលប្រកាន់ខ្ជាប់នូវគោលនយោបាយឯកភាពជាតិ និងសាមគ្គីជាតិ ដើម្បីប្រមូលកំលាំងប្រជាជាតិទាំងមូលពីគ្រប់មជ្ឈដ្ឋាន គ្រប់និន្នាការនយោបាយ ទាំងនៅក្នុង និងនៅក្រៅប្រទេស ក្រោមបាវចនា *«ជាតិ-សាសនា-ព្រះមហាក្សត្រ»* ដើម្បីរួមគ្នាជាធ្លុងមួយសំដៅកសាង ការពារជាតិ និង សមិទ្ធផលសង្គមនៃព្រះរាជាណាចក្រកម្ពុជា ក្នុងបរិការណ៍ ដែលប្រទេសមានឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី សុខ-សន្តិភាព ប្រជាធិបតេយ្យ និង វឌ្ឍនភាពថ្កើងថ្កាន ស្របតាមព្រះរាជតំរិះដ៏ភ្លឺស្វាង និង រុងរឿង ក្រោមព្រះរាជកិច្ចដឹកនាំដ៏ខ្ពង់ខ្ពស់បំផុតនៃព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និង សម្តេចព្រះរាជអគ្គមហេសី **នរោត្តម មុនីនាថ សីហនុ** ជាទីគោរពសក្ការៈ ។

ជាការពិតណាស់ ដោយសារការអនុវត្តន៍យ៉ាងប្តូរប្តេជ្ញឥតរាថយនូវ *«យុទ្ធសាស្ត្រត្រីកោណ»* រាជរដ្ឋាភិបាលកម្ពុជានៅក្នុងរដ្ឋសភានីតិកាលទី ២ កន្លងមកនេះ បានបង្កើតឡើងនូវបរិស្ថានអនុគ្រោះ និង លក្ខខណ្ឌចាំបាច់ និង គ្រប់គ្រាន់ ទាំងក្នុង និង ក្រៅប្រទេស សំរាប់ឱ្យកម្ពុជាអាចបោះជំហាន

ទៅមុខប្រកបដោយក្ដីសង្ឃឹម និង ជំនឿទុកចិត្តយ៉ាងមុតមាំ នៅលើមាគ៌ានៃកំណែទម្រង់ និងការអភិវឌ្ឍន៍ ។ ជោគជ័យនៃការអនុវត្តន៍គោលនយោបាយ *«ឈ្នះ-ឈ្នះ»* បានធ្វើឱ្យប្រទេសកម្ពុជាឆ្លងកាត់ដំណាក់កាលប្រែប្រួលយ៉ាងធំធេងពីចំណុចមួយនៃផែនទីពិភពលោក ដែលប្រកបដោយភាពមិនច្បាស់លាស់ ដោយសារតែកលយុគ សង្គ្រាមរ៉ាំរ៉ៃ ជម្លោះផ្ទៃក្នុង អស្ថិរភាព និង ភាពអន់ថយ ហើយក្លាយទៅជាប្រទេសមួយ ដែលមានសុខសន្តិភាពពេញលេញ មានសុវត្ថិភាព និង សណ្ដាប់ធ្នាប់សង្គម មានការគោរពលទ្ធិប្រជាធិបតេយ្យ គោរពសិទ្ធិនិងសេចក្ដីថ្លៃថ្នូររបស់មនុស្ស ព្រមទាំងមានកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍន៍ ។ ឆ្លងកាត់រយៈពេលដ៏ខ្លីបំផុត ប្រសិនបើប្រៀបធៀបទៅនឹងប្រវត្តិសាស្ត្រនៃប្រទេសជឿនលឿននានា យើងបានបង្ហាញឱ្យដៃគូអន្តរ-ជាតិទាំងឡាយ មើលឃើញដោយគ្មានការសង្ស័យថា កម្ពុជាពិតជាមានសមត្ថភាពគ្រប់គ្រាន់ដើម្បីចូលប្រឡូកដោយស្មើភាព និងស្មើសិទ្ធិ ក្នុងកិច្ច-ការតំបន់ និង ពិភពលោក ។ ប្រការទាំងនេះ បានប្រែក្លាយទៅជាការកើនឡើងនៃជំនឿទុកចិត្តមកលើប្រទេសកម្ពុជា ហើយផ្ដល់ជាផលប្រយោជន៍មកវិញ តាមរយៈការកើនឡើងនៃពាណិជ្ជកម្ម និង លំហូរនៃការវិនិយោគ និងភ្ញៀវទេសចរចូលមកក្នុងប្រទេសកម្ពុជា ដែលជាកត្តាយ៉ាងសំខាន់សំរាប់ជួយបង្កើតការងារ និង បង្កើនចំណូលដល់ពលករកម្ពុជា ដែលផ្ដល់ជាលទ្ធផលចុងក្រោយ គឺការកាត់បន្ថយភាពក្រីក្រ និង ការបង្កើនសុខុមាលភាពរបស់ប្រជាជន ។

ការធានាជម្រុញលើកកំពស់កំណើនសេដ្ឋកិច្ច ការដោះស្រាយការងារសំរាប់ពលករកម្ពុជា ការធានាសមធម៌ និង យុត្តិធម៌សង្គម តាមរយៈ

ផែនការសកម្មភាពអភិបាលកិច្ច និងការធានាប្រសិទ្ធភាពការងាររបស់រាជ-រដ្ឋាភិបាល ក្នុងការអនុវត្តន៍កម្មវិធីកំណែទម្រង់ក្នុងគ្រប់ផ្នែក- គ្រប់វិស័យ ក្នុងទិសដៅកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និង ការអភិវឌ្ឍន៍ប្រកបដោយចិរភាព គឺជារបៀបវារៈនយោបាយដ៏ខ្ពស់បំផុតរបស់រាជរដ្ឋាភិបាល នីតិកាលទី៣ នៃរដ្ឋសភា ។ ក្នុងន័យនេះ ក្នុងនាមជាប្រមុខនៃរាជរដ្ឋាភិបាល ទូលបង្គំ ខ្ញុំ សូមដាក់ចេញនូវ*«យុទ្ធសាស្ត្រចតុកោណ»* ជាឧបករណ៍ទ្រទ្រង់ការអនុវត្តន៍ ***«កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលសំរាប់នីតិកាលទី៣ នៃរដ្ឋសភា»*** ដើម្បីឈានឆ្ពោះទៅសំរេចឱ្យបាននូវ ***ការកាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍន៍ ចីរភាព*** និង ***វិបុលភាព*** ព្រមទាំង ***ភាពសុខដុមរមនា*** និង ***សុភមង្គល*** ជូនប្រជាជនកម្ពុជា ។

## ១.២. អត្ថន័យនយោបាយរបស់យុទ្ធសាស្ត្រចតុកោណ

*ទីមួយ- «យុទ្ធសាស្ត្រចតុកោណ»* នេះ គឺជាការបន្តសកម្មភាព និង ការបន្តពង្រឹងសមិទ្ធផលនានា ដែលរាជរដ្ឋាភិបាលកម្ពុជាសម្រេចបានក្នុងនីតិកាលទី ២ តាមរយៈការអនុវត្តន៍យុទ្ធសាស្ត្រត្រីកោណ និងការជ្រើសរើសចេញពីសមាសធាតុសំខាន់ៗ នៃ *«គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍» (MDGs) «ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ៥ ឆ្នាំ ២០០១-២០០៥»* របស់កម្ពុជាបច្ចុប្បន្ន *«យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ២០០៣-២០០៥»* និងគោលនយោបាយ យុទ្ធសាស្ត្រ ផែនការ និងកម្មវិធីកំណែទម្រង់សំខាន់ៗជាច្រើនទៀត ដែលបានឆ្លងកាត់ការពិគ្រោះយោបល់យ៉ាងទូលំ-ទូលាយ ក្នុងចំណោមមជ្ឈដ្ឋានជាតិ និង អន្តរជាតិ រួមមានក្រសួង- ស្ថាប័ន

រដ្ឋ សង្គមស៊ីវិល និង សហគមន៍អ្នកផ្តល់ជំនួយ ក្នុងទិសដៅកែលំអ និង បង្កើនសមត្ថភាពស្ថាប័នសាធារណៈ លើកស្ទួយអភិបាលកិច្ចល្អ និង ធ្វើទំនើបកម្មរចនាសម្ព័ន្ធសេដ្ឋកិច្ចជាតិ ដើម្បីគោលដៅជម្រុញលើកកំពស់កំណើនសេដ្ឋកិច្ច បង្កើតការងារជូនប្រជាពលរដ្ឋ ធានាសមធម៌ក្នុងសង្គម និង បង្កើនប្រសិទ្ធភាពនៃវិស័យសាធារណៈ ព្រមទាំងរក្សាការពារសម្បត្តិធម្មជាតិ និង សម្បត្តិវប្បធម៌ជាតិ ដែលប្រការទាំងអស់នេះ គឺសុទ្ធតែជាកត្តាគន្លឹះដ៏សំខាន់បំផុត សំរាប់ការអភិវឌ្ឍន៍ប្រកបដោយចិរភាព និង ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។

ទីពីរ- សមាសធាតុគន្លឹះទាំងឡាយនៃ **«យុទ្ធសាស្ត្រចតុកោណ»** ត្រូវបានយកទៅរៀបចំជាមូលដ្ឋានគ្រឹះ នៃគោលនយោបាយសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលនីតិកាលថ្មីនេះ ហើយបានទទួលនូវការឆ្លុះបញ្ចាំងយ៉ាងពេញលេញនៅក្នុង **«កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល សំរាប់នីតិកាល ទី ៣ នៃរដ្ឋសភា»** ។

ទីបី- យ៉ាងណាក៏ដោយ ក្រោយពី **«កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលសំរាប់នីតិកាលទី ៣ នៃរដ្ឋសភា»** ត្រូវបានរៀបចំចប់សព្វគ្រប់លើមូលដ្ឋាននៃការឯកភាពមតិជាឯកច្ឆន្ទ រវាងគណៈបក្សដៃគូទាំងពីរ នៅក្នុងរាជរដ្ឋាភិបាល រាល់ចំណុចគោលនយោបាយសេដ្ឋកិច្ចសំខាន់ៗរបស់ឯកសារ ***«កម្មវិធីនយោបាយ»*** នេះ ក៏ត្រូវបានឆ្លុះបញ្ចាំងត្រឡប់មកវិញ ហើយសម្រិតសម្រាំង និង សម្រួចថែមទៀត នៅក្នុង ***«យុទ្ធសាស្ត្រចតុកោណ»*** តាមរយៈការគូសរំលេចចងក្រង ឱ្យចេញជាកញ្ចប់អាទិភាពនៃ

វិធានការគោលនយោបាយទាំងឡាយ ដែលមានលក្ខណៈជាប្រព័ន្ធ ស៊ីសង្វាក់ ប្រទាក់ក្រឡាគ្នា និង យោងគ្នាទៅវិញទៅមក ។

ដូច្នេះ *«យុទ្ធសាស្ត្រចតុកោណ»* គឺជាការបន្តពី *«យុទ្ធសាស្ត្រត្រីកោណ»* ដែលជាយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលនីតិកាលទី ២ នៃរដ្ឋសភា ហើយដែលមានមុខងារយ៉ាងសមស្របក្នុងការបង្កើតបុព្វលក្ខខណ្ឌសំរាប់ការងើបឈរឡើងពេញជំហររបស់កម្ពុជា ដោយសារថា តាមន័យធរណីមាត្រសាស្ត្រ គេអាចដាក់វត្ថុ ដែលមានជើងបី ឬ *«ត្រីកោណ»* ឱ្យឈរបានគ្រប់ទីកន្លែងទាំងអស់ ទោះក្នុងស្ថានភាពណាក៏ដោយ ។ ចំណែក *«យុទ្ធសាស្ត្រចតុកោណ»* នេះ ត្រូវបានរៀបចំឡើងតាមរចនាសម្ព័ន្ធមុំបួននៃចតុកោណប្រទាក់ក្រឡាគ្នា ហើយផ្សារភ្ជាប់គ្នាគ្រប់ជ្រុងទាំងអស់ ដែលនៅក្នុងផ្នត់គំនិតរបស់មនុស្សទូទៅ គឺតំណាងឱ្យ *«ចិរភាព»* និង *«ស្ថិរភាព»* ឧទាហរណ៍ តុ ឬ កៅអី ដែលមានស្ថិរភាពរឹងមាំ គឺសុទ្ធតែមានជើងបួន ។ ក្នុងន័យនេះ ការសម្រេចបានជោគជ័យ នៅក្នុងការអនុវត្តន៍យុទ្ធសាស្ត្រចតុកោណ នឹងនាំមកឱ្យកម្ពុជានូវស្ថិរភាព និង ការអភិវឌ្ឍន៍ប្រកបដោយចិរភាព ។

តាមទិដ្ឋភាពម្យ៉ាងទៀត *«យុទ្ធសាស្ត្រចតុកោណ»* គឺជា*«របៀបវារៈគោលនយោបាយសេដ្ឋកិច្ច»* នៃ *«កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលសំរាប់នីតិកាលទី ៣ នៃរដ្ឋសភា»* ដែលត្រូវបានយកមករៀបចំលំអិតបន្ថែមដោយអន្លើ ហើយសម្រិតសម្រាំង សម្រួច និង រំលេច ឱ្យចេញជាកញ្ចប់អាទិភាពទៅតាមបណ្តាវិស័យសំខាន់ៗនានា ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និង ជាប្រព័ន្ធ ស៊ីសង្វាក់ ប្រទាក់ក្រឡាគ្នា និង យោងគ្នាទៅវិញទៅ

មក ហើយងាយយល់ និង ងាយគ្រប់គ្រង ដែលអនុញ្ញាតឱ្យរាជរដ្ឋាភិបាល និង ដៃគូអភិវឌ្ឍន៍ ដែលមានការពាក់ព័ន្ធទាំងអស់ អាចប្រើប្រាស់បានជា «ឧបករណ៍គ្រប់គ្រង» (Management tool) សំរាប់ការអនុវត្តន៍របៀបវារៈគោលនយោបាយសេដ្ឋកិច្ចរបស់កម្ពុជា ដែលជាសមាសភាគដ៏ចំបងនៃ *«កម្មវិធីនយោបាយ»* របស់រាជរដ្ឋាភិបាល ។

បើពិនិត្យលើគោលដៅចំបងរបស់យុទ្ធសាស្ត្រចតុកោណ-- ពោលគឺការជម្រុញលើកកំពស់កំណើនសេដ្ឋកិច្ច ការដោះស្រាយការងារ សំរាប់ពលករកម្ពុជា ការធានាសមធម៌ និង យុត្តិធម៌សង្គម និង ការលើកស្ទួយប្រសិទ្ធភាពនៃវិស័យសាធារណៈ តាមរយៈផែនការសកម្មភាពអភិបាលកិច្ច និងកំណែទម្រង់ស៊ីជម្រៅ និងប្រទាក់ក្រឡាគ្នា ក្នុងគ្រប់ផ្នែក គ្រប់វិស័យ-- យើងអាចកំណត់បាវចនានៃការអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលនីតិកាលទី ៣ នៃរដ្ឋសភានេះ ថាជា *«រាជរដ្ឋាភិបាល ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព»* ។

## ១.៣. រចនាសម្ព័ន្ធនៃយុទ្ធសាស្ត្រចតុកោណ

ដូចដែលបានអធិប្បាយខាងលើ យុទ្ធសាស្ត្រនេះត្រូវបានរៀបចំឡើងទៅតាមរចនាសម្ព័ន្ធជាមុំបួននៃចតុកោណដែលប្រទាក់ក្រឡាគ្នា ហើយផ្សារភ្ជាប់គ្នានៅគ្រប់ជ្រុងជ្រោយទាំងអស់ ។ ជារួម សមាសធាតុរបស់ *«យុទ្ធសាស្ត្រចតុកោណ»* នេះ មានដូចតទៅៈ

**ទី១. ស្នូលនៃយុទ្ធសាស្ត្រចតុកោណគឺ** *អភិបាលកិច្ចល្អ* ដែលផ្តោតការយកចិត្តទុកដាក់ទៅលើកំណែទម្រង់បួនយ៉ាង គឺៈ (ទី១). ការប្រយុទ្ធ

ប្រឆាំងនឹងអំពើពុករលួយ (ទី២). កំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ (ទី៣). កំណែទម្រង់រដ្ឋបាលសាធារណៈ រួមមាន ទាំងកម្មវិធីវិមជ្ឈការ និង វិសហមជ្ឈការផង និង (ទី៤). កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ ជាពិសេស គឺកម្មវិធីកាត់រំសាយទ័ព ។

**ទី២. បរិស្ថានគ្របដណ្តប់ សំរាប់ការអនុវត្តន៍យុទ្ធសាស្ត្រចតុកោណ-មូល** ដែលមានបួនយ៉ាងដែរ គឺៈ (ទី១). សុខសន្តិភាព ស្ថិរភាពនយោបាយ និងសណ្តាប់ធ្នាប់សង្គម (ទី២). ភាពជាដៃគូក្នុងការអភិវឌ្ឍន៍រួមមាន ភាពជាដៃគូជាមួយវិស័យឯកជន និង សហគមន៍អ្នកផ្តល់ជំនួយ ព្រមទាំងភាពជាដៃគូជាមួយនឹងសង្គមស៊ីវិល (ទី៣). បរិស្ថានម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលមានលក្ខណៈអនុគ្រោះ និង (ទី៤). សមាហរណកម្មកម្ពុជាទៅក្នុងតំបន់ និង ពិភពលោក ។

**ទី៣. ចតុកោណយុទ្ធសាស្ត្រទាំងបួនសំរាប់ជម្រុញកំណើន** រួមមានៈ (ទី១). ការលើកស្ទួយវិស័យកសិកម្ម (ទី២). ការអភិវឌ្ឍន៍ផ្នែកឯកជន និង ការងារ (ទី៣). ការបន្តស្តារ និង កសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត (ទី៤). ការកសាងសមត្ថភាព និង ការអភិវឌ្ឍន៍ធនធានមនុស្ស ។

**ទី៤.** ចតុកោណយុទ្ធសាស្ត្រនីមួយៗមាន *មុំយុទ្ធសាស្ត្រ* បួនគឺៈ

**ចតុកោណទី១:** ***ការលើកស្ទួយវិស័យកសិកម្ម*** មានៈ (ទី១). ការលើកកំពស់ផលិតភាព និង ពិពិធកម្ម *(Diversification)* វិស័យកសិកម្ម (ទី២). កំណែទម្រង់ដីធ្លី និង ការបោសសំអាតមីន (ទី៣). កំណែទម្រង់វិស័យនេសាទ និង ជលផល និង (ទី៤). កំណែទម្រង់ព្រៃឈើ ។

**ចតុកោណទី ២:** *ការបន្តស្តារ និង កសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត* មានៈ (ទី១). ការបន្តស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ (ផ្លូវគោក ផ្លូវទឹក និង ផ្លូវអាកាស) (ទី២). ការគ្រប់គ្រងធនធានទឹក និង ប្រព័ន្ធធារាសាស្ត្រ (ទី៣). ការអភិវឌ្ឍន៍វិស័យថាមពល និង បណ្តាញអគ្គិសនី (ទី៤). ការអភិវឌ្ឍន៍បច្ចេកវិទ្យាពត៌មាន និង ទូរគមនាគមន៍ ។

**ចតុកោណទី ៣:** *ការអភិវឌ្ឍន៍ផ្នែកឯកជន និង ការងារ* មានៈ (ទី១). ការពង្រឹងវិស័យឯកជន និង ការទាក់ទាញទុនវិនិយោគ (ទី២). ការលើកស្ទួយសហគ្រាសធុនតូច និងមធ្យម (ទី៣). កាបង្កើតការងារ និង ការធានាលក្ខខណ្ឌការងារល្អប្រសើរជូនដល់កម្មករ និង និយោជិត (ទី៤). ការរៀបចំប្រព័ន្ធសុវត្ថិភាពសង្គម សំរាប់មន្ត្រី បុគ្គលិក កម្មករ ។

**ចតុកោណទី ៤:** *ការកសាងសមត្ថភាព និង ការអភិវឌ្ឍន៍ធនធានមនុស្ស* មានៈ (ទី១). ការលើកកំពស់ និង ពង្រឹងគុណភាពនៃវិស័យអប់រំ (ទី២). ការលើកស្ទួយសេវាសុខាភិបាល (ទី៣). ការអនុវត្តគោលនយោបាយយេនឌ័ *(Gender Policy)* និង (ទី៤). ការអនុវ គោលនយោបាយប្រជាជន ។

(សូមមើល **គំនូសបំព្រួញនៃយុទ្ធសាស្ត្រចតុកោណ** នៅក្នុងទំព័

## គំនូរបំព្រួញស្តីពី "យុទ្ធសាស្ត្រចតុកោណ"



# ផ្នែកទី២

## អាទិភាពនៃគោលនយោបាយសេដ្ឋកិច្ច

ឃឃឃ៙ល្លល

### ២.១. ស្នូលនៃយុទ្ធសាស្ត្រចតុកោណ គឺ អភិបាលកិច្ចល្អ

អភិបាលកិច្ចល្អ គឺជាបុរេលក្ខណៈវិនិច្ឆ័យសំខាន់បំផុតមួយ ដើម្បីធានាឱ្យមានការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយចិរភាព មានសមធម៌ និង យុត្តិធម៌សង្គម ។ អភិបាលកិច្ចល្អ តម្រូវឱ្យមាននូវការចូលរួមយ៉ាងទូលំទូលាយ មានការលើកកំពស់ការចែករំលែកពត៌មាន មានគណនេយ្យភាព និង តម្លាភាព មានលក្ខណៈស្មើភាព និង ការមិនបោះបង់ចោលនូវបុគ្គលណាម្នាក់ ហើយនិងមានការប្រតិបត្តិតាមវិធាននៃច្បាប់ ។ ក្នុងន័យនេះ អភិបាលកិច្ចល្អ នឹងធានាកាត់បន្ថយអំពើពុករលួយ ឱ្យស្ថិតនៅក្នុងកំរិតអប្បបរមា មតិ- យោបល់របស់អ្នកភាគតិច នឹងត្រូវបានយកមកពិចារណា ហើយសម្លេងរបស់ជនងាយរងគ្រោះសឹងតែទាំងអស់នៅក្នុងសង្គម នឹងត្រូវបានបញ្ចូលក្នុងការធ្វើសេចក្តីសំរេចចិត្ត ។ ដូច្នេះ អភិបាលកិច្ចល្អ គឺជាសំណូមពរ និង ជាសេចក្តីត្រូវការរបស់សង្គមកម្ពុជា ទាំងក្នុងពេលបច្ចុប្បន្ន និង ក្នុងពេលអនាគត ។

ដើម្បីសម្រេចគោលបំណងនេះ រាជរដ្ឋាភិបាលនឹងផ្តោតការយកចិត្តទុកដាក់ទៅលើការអនុវត្តន៍ប្រកបដោយប្រសិទ្ធភាព នូវផែនការសកម្មភាពអភិបាលកិច្ចរបស់ខ្លួន ដែលគ្របដណ្តប់លើកំណែទម្រង់បួនយ៉ាងដែល

មានការពាក់ព័ន្ធគ្នាទៅវិញទៅមក ក្នុងនោះរួមមានៈ (ទី១). ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ (ទី២). កំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ (ទី៣). កំណែទម្រង់រដ្ឋបាលសាធារណៈ រួមមានទាំងកម្មវិធីវិមជ្ឈការ និង វិសហមជ្ឈការផង (ទី៤). កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ ពិសេសគឺកម្មវិធីកាត់បន្ថយទ័ព ។

## (ទី១). ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ

រាជរដ្ឋាភិបាល បានជ្រើសរើសយកយុទ្ធសាស្ត្រប្រឆាំងនឹងអំពើពុករលួយ ដោយដាក់ចេញនូវវិធានការជាក់ស្តែង ដែលអាចលុបបំបាត់ឫសគល់នៃអំពើពុករលួយ ។ យុទ្ធសាស្ត្រនេះ ត្រូវដាក់ឱ្យអនុវត្តដោយមានទាំងមធ្យោបាយ និង ធនធានគ្រប់គ្រាន់ដើម្បីទប់ស្កាត់ និង បង្ក្រាបជាអតិបរមាដល់អ្នកប្រព្រឹត្តអំពើពុករលួយ ពីព្រោះ ប្រសិនបើមានតែច្បាប់ បទបញ្ញត្តិ និង ក្រមសីលធម៌មួយមុខ គឺមិនអាចសំរេចបានជោគជ័យទេ ។ ក្នុងករណីនេះ ចាំបាច់ត្រូវមានយន្តការ ដើម្បីពង្រឹងការអនុវត្តន៍ច្បាប់ឱ្យមានប្រសិទ្ធភាពថែមទៀត ។

ដើម្បីសម្រេចបានគោលដៅនេះ រាជរដ្ឋាភិបាលនឹងជម្រុញការអនុមតិច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ និង ការបង្កើតស្ថាប័នឯករាជ្យអព្យាក្រឹត្យមួយសំរាប់ប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ឱ្យបានឆាប់តាមតែអាចធ្វើបាន ព្រមទាំងជម្រុញការលើកកំពស់ប្រសិទ្ធភាព តម្លាភាព និង គណនេយ្យភាព ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេសតាមរយៈការពង្រឹងការងារសវនកម្ម និង លទ្ធកម្មសាធារណៈ ក៏ដូចជាការជម្រុញ

អនុវត្តកំណែទម្រង់ ដែលមានការពាក់ព័ន្ធគ្រប់វិស័យ ដើម្បីធានាអភិបាលកិច្ចល្អ ជាពិសេសគឺការអនុវត្តន៍ផែនការសកម្មភាពអភិបាលកិច្ចរបស់រាជរដ្ឋាភិបាល ដែលត្រូវបានរៀបចំឡើងដោយមានការចូលរួមយ៉ាងទូលំទូលាយពីសំណាក់ក្រសួង-ស្ថាប័នរដ្ឋ សង្គមស៊ីវិល និង ដៃគូអ្នកផ្ដល់ជំនួយ ។ ចាប់ពីនីតិកាលទី ៣ នេះទៅ រាជរដ្ឋាភិបាលអនុញ្ញាតឱ្យក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធដោយផ្ទាល់ អាចពិនិត្យបាននូវរាល់កិច្ចសន្យាពាណិជ្ជកម្ម និង កិច្ចសន្យាសម្បទានលើធនធានធម្មជាតិ និង លើសម្បត្តិរដ្ឋ ។

## (ខ២). កំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌

រាជរដ្ឋាភិបាលគោរព និង លើកស្ទួយឯករាជ្យ និង អព្យាក្រឹត្យភាពនៃប្រព័ន្ធតុលាការ ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ ។ ក្នុងគោលដៅនេះ ឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវមានដំណើរការប្រព្រឹត្តិទៅនៅក្នុងឯករាជ្យពិតប្រាកដ ។ រាជរដ្ឋាភិបាលខិតខំជម្រុញការកែប្រព័ន្ធច្បាប់ និង តុលាការឱ្យបានឯករាជ្យ តាមរយៈការអនុវត្តន៍ឯកសារគោលនយោបាយ និង យុទ្ធសាស្ត្រ ដែលក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ បានរៀបចំឡើង ឱ្យមានជំនឿទុកចិត្តពីមជ្ឈដ្ឋានជាតិ និង អន្តរជាតិ ដោយសហការយ៉ាងជិតស្និទ្ធជាមួយនឹងដៃគូអ្នកផ្ដល់ជំនួយនានា ក្នុងទិសដៅពង្រឹងនីតិរដ្ឋ បង្កើនយុត្តិធម៌នៅក្នុងសង្គម កាត់បន្ថយអំពើពុករលួយ ឈានទៅលុបបំបាត់វប្បធម៌និទណ្ឌភាព ព្រមទាំងពង្រឹងវប្បធម៌សន្តិភាព និង វប្បធម៌នៃការគោរពច្បាប់ ។ ជាក់ស្ដែង រាជរដ្ឋាភិបាលនឹងរៀបចំចេញជាគំរោងអាទិភាព ដើម្បីកែលំអប្រព័ន្ធច្បាប់ និង តុលាការជាជំហានៗ ដែលផ្ដោតជាសំខាន់ទៅលើការបញ្ចប់ការតាក់តែង ដើម្បីដាក់ឆ្លងរដ្ឋសភានូវបណ្ដាច្បាប់ ដែល

មានលក្ខណៈជាមូលដ្ឋាន មានជាអាទិ៍ច្បាប់លក្ខន្តិកៈចៅក្រម ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ក្រមព្រហ្មទណ្ឌ នីតិវិធីព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី និង ក្រមស្តីពីនីតិវិធីរដ្ឋប្បវេណី ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃសារការី និង ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់អាជ្ញាសាលា ។ ច្បាប់ និង លិខិតបទដ្ឋានមួយចំនួនទៀត ក៏នឹងត្រូវបានបង្កើតឡើង ដើម្បីបំពេញបន្ថែមទៅលើក្របខ័ណ្ឌគតិយុត្តិបច្ចុប្បន្ន ដែលជាលក្ខខណ្ឌចាំបាច់ក្នុងក្របខ័ណ្ឌអាស៊ាន និង អង្គការពាណិជ្ជកម្មពិភពលោក ជាពិសេស រាជរដ្ឋាភិបាល នឹងរៀបចំឱ្យមានតុលាការឯកទេសមួយចំនួនតាមតម្រូវការចាំបាច់ មានជាអាទិ៍ តុលាការពាណិជ្ជកម្ម តុលាការអនីតិជន តុលាការការងារ និងតុលាការរដ្ឋបាល ។ ក្រៅពីនោះ តុលាការគំរូ ក៏នឹងត្រូវបានរៀបចំបង្កើតឡើងជាជំហានៗ ក្នុងទិសដៅបង្កើនគុណភាព និង ប្រសិទ្ធភាពនៃសេវាយុត្តិធម៌ ។ អាទិភាពដ៏សំខាន់មួយទៀត គឺការពង្រឹងសមត្ថភាព និងការទទួលខុសត្រូវរបស់ចៅក្រម តាមរយៈការបង្កើតលក្ខន្តិកៈចៅក្រម ការពង្រឹងវិន័យតាមក្រមសីលធម៌ និង តាមការបណ្តុះបណ្តាលដំបូង និងការបណ្តុះបណ្តាលបន្ត ។ ម្យ៉ាងវិញទៀត រាជរដ្ឋាភិបាលនឹងបង្កើតសាលាបណ្តុះបណ្តាលក្រឡាបញ្ជី និង សាលាបណ្តុះបណ្តាលអាជ្ញាសាលា និងសារការី ។ នគរបាលយុត្តិធម៌ នឹងត្រូវបានទទួលការបណ្តុះបណ្តាល និងការគ្រប់គ្រងដោយហ្មត់ចត់ ។ ព្រមជាមួយគ្នានេះ រាជរដ្ឋាភិបាលនឹងយកចិត្តទុកដាក់ខ្ពស់ចំពោះការផ្តល់ជំនួយគតិយុត្តិ (ឧទាហរណ៍ តាមរយៈការផ្តល់មេធាវី) ដល់ជនក្រីក្រ ដើម្បីស្វះស្វែងរកយុត្តិធម៌ និង ការពារផលប្រយោជន៍របស់ពួកគេ ។ ក្រៅពីនេះទៀត រាជរដ្ឋាភិបាលនឹងលើកកំពស់

យន្តការដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការជូនប្រជាពលរដ្ឋ ពិសេសចំពោះបញ្ហាដីធ្លីមិនទាន់ចុះបញ្ជីសុរិយោដី ។

### (ទី៣). កំណែទម្រង់រដ្ឋបាលសាធារណៈ

រាជរដ្ឋាភិបាលយល់ច្បាស់ថា កិច្ចការពង្រឹងសមត្ថភាពស្ថាប័ន គឺជាគន្លឹះនៃការអភិវឌ្ឍន៍។ រដ្ឋបាល និងមុខងារសាធារណៈ ត្រូវមានលក្ខណៈអព្យាក្រឹត្យ តម្លាភាព អាចឆ្លើយតបទាន់ពេលវេលាទៅនឹងតម្រូវការ ហើយត្រូវមានសមត្ថភាព និងការទទួលខុសត្រូវខ្ពស់ ។ រាជរដ្ឋាភិបាលបានអនុម័តកម្មវិធីជាតិសំរាប់កែទម្រង់រដ្ឋបាល ដើម្បីប្រែក្លាយរដ្ឋបាល និង មុខងារសាធារណៈឱ្យក្លាយទៅជាដៃគូដ៏មានប្រសិទ្ធភាព ក្នុងការអនុវត្តន៍កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ។

នៅលើមូលដ្ឋាននៃគោលដៅនេះ រាជរដ្ឋាភិបាលនឹងផ្តោតការយកចិត្តទុកដាក់ទៅលើការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ប្រកបដោយគុណភាព និង ប្រសិទ្ធភាព ក្នុងវិស័យអាទិភាព ៤ នៃសេវាសាធារណៈ គឺៈ (ទី១). សេវាពាក់ព័ន្ធនឹងអធិបតេយ្យភាពរបស់រដ្ឋ (ឧទាហរណ៍ អត្រានុកូលដ្ឋាន លិខិតអនុញ្ញាតផ្សេងៗ ប័ណ្ណកម្មសិទ្ធិលើដីធ្លី) (ទី២). សេវាពាក់ព័ន្ធទៅនឹងការវិនិយោគ (ទី៣). សេវាមូលដ្ឋាន (អប់រំ និងសុខាភិបាល) (ទី៤). សេវាពាក់ព័ន្ធនឹងចំណូល- ចំណាយរបស់រដ្ឋ ។

នីតិវិធីនៃការទទួលសេវាសាធារណៈ នឹងត្រូវបានសម្រួល និងធ្វើឱ្យមានភាពសាមញ្ញ តាមរយៈ ការលុបបំបាត់ការងារដែលជាន់គ្នា ការកាត់បន្ថយការិយាធិបតេយ្យ ការអនុវត្តន៍គោលនយោបាយវិសហមជ្ឈការ វិមជ្ឈការបច្ចេកទេស វិមជ្ឈការថ្នាក់ឃុំ- សង្កាត់ យន្តការ *«ច្រកចេញ- ចូល*

*តែមួយ»* ព្រមទាំងការបង្កើតការិយាល័យប្រជាពលរដ្ឋ ។ នីតិវិធីទាំងអស់នឹងត្រូវបានបញ្ចូលជាជំហានៗ ទៅក្នុងប្រព័ន្ធបច្ចេកវិទ្យាពត៌មាន ដើម្បីពង្រឹងតម្លាភាព និង ចូលរួមកាត់បន្ថយអំពើពុករលួយ ។ ការយកចិត្តទុកដាក់ជាពិសេស នឹងត្រូវបានផ្តល់ទៅលើការពង្រឹងការងារគ្រប់គ្រងមន្ត្រី-រាជការ តាមរយៈការបង្កិតរដ្ឋបាលសាធារណៈបច្ចុប្បន្ន ឱ្យកាន់តែខិតជិតទៅរកប្រជាពលរដ្ឋ តាមរយៈគោលនយោបាយវិសហមជ្ឈការ និង វិមជ្ឈការពិសេសការផ្ទេរអំណាចពីថ្នាក់លើមកថ្នាក់ក្រោមឱ្យបានឆាប់រហ័ស ហើយកំណត់ច្បាស់លាស់នូវតួនាទី សិទ្ធិអំណាច និង ការទទួលខុសត្រូវរបស់អាជ្ញាធរថ្នាក់ខេត្ត-ក្រុង ស្រុក-ខណ្ឌ ឃុំ-សង្កាត់ ការប្រើប្រាស់ប្រព័ន្ធពត៌មានវិទ្យា ការបន្តអនុវត្តយុទ្ធសាស្ត្រសនិទានកម្មមុខងារសាធារណៈដើម្បីតម្លើងបៀវត្សជូនមន្ត្រីរាជការទូទៅជាជំហានៗ សំរាប់សម្រួលជីវភាពឱ្យបានធូរស្រាលសមរម្យថ្លៃថ្នូរ ឱ្យបានពី ១០ ទៅ ១៥% ក្នុងមួយឆ្នាំៗ ។ រាជរដ្ឋាភិបាលចាត់ទុកការអនុវត្តន៍កម្មវិធីវិមជ្ឈការថ្នាក់ឃុំ-សង្កាត់ថា ជាគន្លឹះសំរាប់ពង្រឹងលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន សំរាប់លើកកំពស់គុណភាពសេវាសាធារណៈ និង សំរាប់ជម្រុញកិច្ចអភិវឌ្ឍន៍គ្រប់ផ្នែកនៅមូលដ្ឋាន ដោយមានការចូលរួមពីសំណាក់មូលដ្ឋានខ្លួនឯងផ្ទាល់ ។ អាទិ-ភាពចំបងនៅក្នុងវិស័យនេះ គឺការកសាងសមត្ថភាពគ្រប់គ្រងនៅថ្នាក់មូលដ្ឋាន និង ការផ្តល់ប្រភពធនធានហិរញ្ញវត្ថុសមស្រប ព្រមទាំងការលើកស្ទួយវប្បធម៌ចូលរួមរបស់ប្រជាពលរដ្ឋ នៅក្នុងកិច្ចការទាំងអស់នេះ ។ ពិតណាស់ថា ការអនុវត្តន៍វិមជ្ឈការ ត្រូវដើរទន្ទឹមគ្នានឹងការជម្រុញវិសហ-មជ្ឈការ ដែលសំដៅជាពិសេសទៅលើការកសាងសមត្ថភាពថ្នាក់ខេត្ត-

ក្រុង និងស្រុក-ខ័ណ្ឌ ដើម្បីធានាឱ្យមានភាពរលូន ព្រមទាំងការជួយទ្រទ្រង់គ្នា និង បំពេញឱ្យគ្នាទៅវិញទៅមក ក្នុងការងាររបស់ថ្នាក់ខេត្ត-ក្រុង និង ស្រុក-ខ័ណ្ឌ ជាមួយនឹងថ្នាក់មូលដ្ឋាន ។ ក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាល នឹងរៀបចំប្រធាន អនុប្រធាន និង សមាជិកភូមិ ឱ្យបានឆាប់តាមតែអាចធ្វើបាន ស្របទៅតាមគោលការណ៍វិមជ្ឈការនៅឃុំ-សង្កាត់ ។

## (ទី៤). កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ

ដើម្បីសម្រេចកិច្ចការនេះ រាជរដ្ឋាភិបាលបន្តអនុវត្តគោលនយោបាយ ដែលបានចែងក្នុងសៀវភៅ «ស» របស់កងយោធពលខេមរភូមិន្ទ រួមបញ្ចូលទាំងការចែកដីសម្បទានដើម្បីគោលដៅសង្គមកិច្ច ដល់យោធិនរំសាយ ដែលខ្វះខាតដី និង មានបំណងសុំដីសំរាប់សាងសង់លំនៅដ្ឋាន ឬ/និងធ្វើកសិកម្មជាលក្ខណៈគ្រួសារ តាមតម្រូវការសមស្រប តាមស្មារតីនៃអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច ។ ទន្ទឹមនឹងនោះ រាជរដ្ឋាភិបាលនឹងបន្តកំណែទម្រង់ ដើម្បីកសាង និងពង្រឹងកងកម្លាំងនគរបាលជាតិ ឱ្យទៅជាកងកម្លាំង មានវិជ្ជាជីវៈជំនាញ និង មានបច្ចេកវិទ្យាទំនើប មានស្មារតីទទួលខុសត្រូវ គោរពប្រតិបត្តិច្បាប់ហ្មឺងម៉ាត់ គោរពសិទ្ធិមនុស្ស បំរើប្រជាជនដោយស្មោះត្រង់ មានសមត្ថភាព សម្រេចបានល្អនូវភារកិច្ចគ្រប់គ្រង និងថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ការពារអាយុជីវិត និង ទ្រព្យសម្បត្តិរបស់ប្រជាជន ព្រមទាំងរក្សាបាននូវភាពសុខដុមរមនា នៅក្នុងសង្គម ។

## ២.២. បរិស្ថានគ្រប់ជណ្តប់ សំរាប់ការអនុវត្តន៍យុទ្ធសាស្ត្រទាំងមូល

### (ទី១). សុខសន្តិភាព ស្ថិរភាពនយោបាយនិងសណ្តាប់ធ្នាប់សង្គម

សន្តិភាព ស្ថិរភាពនយោបាយ សណ្តាប់ធ្នាប់សង្គម គឺជាលក្ខខណ្ឌមិនអាចខ្វះបាន សំរាប់ការពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ការអភិវឌ្ឍន៍ប្រកបដោយចីរភាព និង ការកាត់បន្ថយភាពក្រីក្រ ។ ដូច្នេះ រាជរដ្ឋាភិបាលនឹងបន្តការងាររបស់ខ្លួន ក្នុងគោលដៅបន្តពង្រឹងថែមទៀត នូវសុខសន្តិភាព ស្ថិរភាពនយោបាយ សណ្តាប់ធ្នាប់សង្គម ជូនដល់ប្រជាពលរដ្ឋ ដើម្បីឆ្លុះបញ្ចាំងពីការបោះជំហានរបស់កម្ពុជា ឆ្ពោះទៅរកការអភិវឌ្ឍន៍ និងភាពកាន់តែចំរើនរុងរឿង ដោយប្តេជ្ញាដោះស្រាយឱ្យអស់នូវផលវិបាកនៃសង្គ្រាម របបប្រល័យពូជសាសន៍ និង ជម្លោះផ្ទៃក្នុង ដែលបានបំផ្លិចបំផ្លាញ និងញាំញីកម្ពុជា ក្នុងរយៈពេលជិតបីទសវត្សរ៍កន្លងទៅនេះ ។

ក្នុងន័យនេះ សុខសន្តិភាព ស្ថិរភាពនយោបាយ និង សណ្តាប់ធ្នាប់សង្គម គឺជាមូលដ្ឋានគ្រឹះនៃការងារកសាង និង កំណែទម្រង់រដ្ឋ ។ ដូច្នេះ ភារកិច្ចចំបងរបស់រាជរដ្ឋាភិបាល គឺត្រូវពង្រឹងកោសិកាសន្តិភាពឱ្យផ្សារភ្ជាប់គ្នាល្អ ដោយប្រើប្រាស់គ្រប់មធ្យោបាយទាំងអស់ ។ ការពង្រឹងសុខសន្តិភាព ស្ថិរភាពនយោបាយ និង សណ្តាប់ធ្នាប់សង្គម នឹងបង្កើតនូវ *«របភាពជាក់ស្តែង»* មួយរបស់កម្ពុជា ក្នុងការបង្កើនជំនឿទុកចិត្តពីសំណាក់វិនិយោគិន និងទេសចរ ក៏ដូចជាក្នុងការបង្កលក្ខណៈឱ្យប្រជាពលរដ្ឋអាចរស់នៅ ប្រកប

របរអាជីវកម្មតាមធម្មតា និង ចូលរួមចំណែកនៅក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច យ៉ាងសកម្ម តាមសមត្ថភាពរៀងៗខ្លួន ។

## (ទី២). ភាពជាដៃគូនៅក្នុងការអភិវឌ្ឍន៍

រាជរដ្ឋាភិបាលផ្តល់អាទិភាពយ៉ាងខ្លាំង ដល់ការពង្រឹងភាពជាដៃគូជាមួយតួអង្គអភិវឌ្ឍន៍ទាំងអស់ ដែលក្នុងនោះរួមមាន ភាពជាដៃគូជាមួយនឹងសហគមន៍អ្នកផ្តល់ជំនួយ វិស័យឯកជន និង សង្គមស៊ីវិល ។ យន្តការនៃភាពដៃគូជាមួយសហគមន៍អ្នកផ្តល់ជំនួយ ត្រូវបានរៀបចំឡើងដោយឈរលើមូលដ្ឋាននៃសេចក្តីសម្រេចចិត្ត របស់មហាសន្និបាតអង្គការសហប្រជាជាតិ គោលការណ៍របស់គណកម្មការជំនួយដើម្បីអភិវឌ្ឍន៍ (DAC) នៃអង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និង អភិវឌ្ឍន៍ (OECD) ក៏ដូចជាការផ្តួចផ្តើមគំនិតនានារបស់ធនាគារពិភពលោក និង កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ។

រាជរដ្ឋាភិបាលចាត់ទុកផ្នែកឯកជន ជាក្បាលម៉ាស៊ីននៃកំណើន ។ ដូច្នេះ ការពង្រឹងភាពជាដៃគូរវាងរាជរដ្ឋាភិបាល និង ផ្នែកឯកជន ត្រូវមានភាពរលូនជាមួយការធ្វើអន្តរាគមន៍ប្រកបដោយវិចារណញ្ញាណរបស់រដ្ឋ ក្នុងវិស័យសេដ្ឋកិច្ច គួបផ្សំទៅនឹងការរៀបចំ និងអនុវត្តន៍យ៉ាងហ្មត់ចត់ នូវបទបញ្ញត្តិច្បាប់ ព្រមទាំងការគាំទ្រ និង ការសម្រួលប្រកបដោយប្រសិទ្ធភាពពីសំណាក់ស្ថាប័នរដ្ឋដែលមានការពាក់ព័ន្ធ ។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលនឹងបន្តពង្រឹង «វេទិការាជរដ្ឋាភិបាល និង វិស័យឯកជន» ឱ្យក្លាយទៅជា

យន្តការនៃភាពជាដៃគូរវាងវិស័យសាធារណៈ និង វិស័យឯកជន ប្រកប ដោយប្រសិទ្ធភាពកាន់តែខ្ពស់ជាងមុន ។

រាជរដ្ឋាភិបាលបន្តពង្រឹងកិច្ចសហប្រតិបត្តិការរវាងរដ្ឋ និង សង្គម ស៊ីវិល ដោយឈរលើគោលការណ៍នីតិរដ្ឋ ដើម្បីពង្រឹងលទ្ធិប្រជាធិបតេយ្យ សិទ្ធិសេរីភាព សណ្តាប់ធ្នាប់សង្គម និងការគោរពច្បាប់ ។ សង្គមស៊ីវិលត្រូវ មានតួនាទីជាដៃគូមួយដ៏មានប្រសិទ្ធភាពរបស់រាជរដ្ឋាភិបាល ក្នុងការកសាង ប្រទេសជាតិ ។ ក្នុងទស្សនៈនេះ រាជរដ្ឋាភិបាលលើកទឹកចិត្តតាមគ្រប់រូប-ភាពចំពោះអង្គការមិនមែនរដ្ឋាភិបាល និង សមាគមស្របច្បាប់នានា ដែល កំពុងធ្វើសកម្មភាពបំរើផលប្រយោជន៍ប្រជាពលរដ្ឋនៅទូទាំងប្រទេស ។ រាជរដ្ឋាភិបាល ស្វាគមន៍ការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាលអន្តរ-ជាតិ ក្នុងដំណើរការស្តារ និង អភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច និង ការគាំ-ពារលើកស្ទួយការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យ និង ការគោរពសិទ្ធិមនុស្ស ។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលនឹងបន្តជម្រុញការបង្កើត និង អនុវត្តន៍ច្បាប់ ស្តីពីអង្គការមិនមែនរដ្ឋាភិបាល និង សមាគម ដោយមានការពិគ្រោះ-យោបល់ជាមួយនឹងស្ថាប័ន និង អង្គការពាក់ព័ន្ធ ។

## (ទី៣). បរិស្ថានម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលមាន លក្ខណៈអនុគ្រោះ

ផ្អែកលើមូលដ្ឋាននៃសមិទ្ធផលការងារ ដែលសម្រេចបានពីមុនមក ក្នុងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ រាជរដ្ឋាភិបាល នឹងបន្តពុះពារ ដើម្បីសម្រេចឱ្យបាននូវគោលដៅនៃកំណើនសេដ្ឋកិច្ចខ្ពស់

ក្នុងអត្រា ៦ ទៅ ៧% ក្នុងមួយឆ្នាំ ក្នុងបរិការណ៍នៃអត្រាអតិផរណាទាបក្នុងកម្រិតតួលេខតែមួយខ្ទង់ អត្រាប្តូរប្រាក់មានស្ថិរភាពល្អ ហើយទុនបំរុងរបស់ជាតិក៏មានការកើនឡើងជាប្រចាំ ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនឹងបន្តអនុវត្តគោលនយោបាយរូបិយវត្ថុប្រុងប្រយ័ត្ន និង អត្រាប្តូរប្រាក់អណ្តែតដែលផ្អែកលើមូលដ្ឋាននៃគោលការណ៍ទីផ្សារ ។ គោលនយោបាយបដិ-ដុល្លារូបនីយកម្ម នឹងត្រូវបានអនុវត្តបន្តក្នុងជំហានដ៏ប្រុងប្រយ័ត្ន ស្របទៅតាមសភាពការណ៍វិវត្តន៍នៃសេដ្ឋកិច្ចជាតិ និង អន្តរជាតិ ។

ការប្រកាន់ខ្ជាប់នូវវិន័យនៅក្នុងការគ្រប់គ្រងថវិកា មានសារសំខាន់ខ្លាំងណាស់ សំរាប់ការបង្កើតឡើងនូវបរិស្ថានម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុដែលមានលក្ខណៈអនុគ្រោះ ចំពោះការខិតខំកសាងមូលដ្ឋានគ្រឹះដ៏រឹងប៉ឹង និង មាំមួននៃសេដ្ឋកិច្ចជាតិ ដើម្បីធានាកំណើនមួយប្រកបទៅដោយចិរភាព និង មានសមធម៌ ។ មើលឃើញយ៉ាងដូច្នេះ រាជរដ្ឋាភិបាលប្តេជ្ញាបន្តខិតខំពង្រឹងការប្រមូលចំណូលគ្រប់ប្រភេទ ទាំងចំណូលពន្ធដារ ទាំងចំណូលមិនមែនពន្ធដារ ។ កិច្ចការនេះ រួមបញ្ចូលការអនុវត្តន៍យ៉ាងហ្មត់ចត់នូវច្បាប់ស្តីពីសារពើពន្ធ ការប្រឆាំងនឹងអំពើពុករលួយ និងការគេចវេះពន្ធ ការបន្តអនុវត្តវប្បធម៌គ្មានការលើកលែងពន្ធ ការពង្រីកមូលដ្ឋានពន្ធដារ ការពង្រឹងសមត្ថភាពរបស់រដ្ឋបាលពន្ធដារ និងរបស់រដ្ឋបាលគយ និងរដ្ឋាករ និងការ-ធានាគ្រប់គ្រងដោយត្រឹមត្រូវ និង ហ្មត់ចត់នូវទ្រព្យសម្បត្តិគ្រប់ប្រភេទរបស់រដ្ឋ រួមទាំងទ្រព្យសម្បត្តិរូបិយ ទាំងទ្រព្យសម្បត្តិអរូបិយ ក្នុងនោះមានទ្រព្យ-សម្បត្តិរបស់ក្រុមហ៊ុនរដ្ឋ និង ក្រុមហ៊ុនចំរុះរដ្ឋ ។ រាជរដ្ឋាភិបាលនឹងជម្រុញអនុវត្តកម្មវិធីកែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពិសេស

តាមរយៈការបន្តគោលនយោបាយវិចារណកម្មចំណាយ ដោយឈរលើគោលការណ៍តម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពសេដ្ឋកិច្ច និងការពង្រឹងយន្តការសវនកម្ម និង លទ្ធកម្មសាធារណៈ ដោយផ្តល់អាទិភាពខ្ពស់លើចំណាយក្នុងវិស័យសង្គមកិច្ច សេដ្ឋកិច្ច និងលើការវិនិយោគសាធារណៈ ជាពិសេសក្នុងផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ។ រាល់ប្រតិបត្តិការថវិកា ទាំងក្នុងផ្នែកចំណូល ទាំងក្នុងផ្នែកចំណាយ ត្រូវតែបានធ្វើឡើងស្របទៅតាមវិធាន និង នីតិវិធីជាធរមាន ។

នៅលើមូលដ្ឋាននៃគោលនយោបាយជាអាទិភាពខាងលើនេះ ក្នុងនាមជាប្រមុខនៃរាជរដ្ឋាភិបាលសំរាប់នីតិកាលទី ៣ នៃរដ្ឋសភា ខ្ញុំសូមដាក់ចេញនូវវិន័យដប់យ៉ាងក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលគ្រប់សមាជិក- សមាជិកានៃរាជរដ្ឋាភិបាល មានកាតព្វកិច្ចត្រូវគោរពយ៉ាងខ្ជាប់ខ្ជួន និង ដោយហ្មឺងម៉ាត់បំផុត មិនអាចធ្វេសប្រហែស និង មិនអាចលើកលែងបានគ្រប់ពេលវេលា គឺ÷

**វិន័យទី ១**: ត្រូវបន្តប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវការមិនអនុញ្ញាតឱ្យមាន «វប្បធម៌រួចពន្ធ និង លើកលែងពន្ធ» នៅក្នុងប្រទេសកម្ពុជា ។

**វិន័យទី ២**: ត្រូវខិតខំប្រមូលចំណូលគ្រប់ប្រភេទ ឱ្យបានគ្រប់តាមផែនការ ឬ លើសផែនការ ។

**វិន័យទី ៣**: ត្រូវបង់ចំណូលទាំងអស់ចូលរតនាគារជាតិភ្លាមៗ ឱ្យបានទាន់ពេល ។ ហាមដាច់ខាតការរក្សាទុកចំណូលសំរាប់ចំណាយនៅក្រៅក្របខ័ណ្ឌថវិកាជាតិ ទោះជាតាមរយៈយន្តការចំណូលព្រម- ចំណាយព្រមក្តី តាមរយៈការឱ្យក្រុមហ៊ុនប្រើមុន ហើយចាំកាត់ចំណូលសងតាមក្រោយក្តី ។

**ទិន័យទី ៤**: ត្រូវក្លាហាន និងដាច់ខាត ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើរត់គេចពន្ធគ្រប់ប្រភេទ និង ក្នុងការតឹងទារបំណុលពីអ្នកដែលជំពាក់បំណុលរដ្ឋ ជាពិសេសពីអ្នកជំពាក់បំណុលពន្ធ ។

**ទិន័យទី ៥**: ត្រូវតម្រង់ចំណាយឱ្យចំទិសដៅអាទិភាពនៃការអភិវឌ្ឍន៍ ហើយហ្មឹងម៉ាត់ក្នុងការត្បិតត្បៀតចំណាយដែលមិនចាំបាច់ ឬ មិនទាន់ចាំបាច់ និង ត្រូវសន្សំសំចៃក្នុងការចាយវាយ ហើយត្រូវលើកកំពស់ស្មារតីប្រឆាំងនឹងភាពខ្ជះខ្ជាយ ។

**ទិន័យទី ៦**: ត្រូវពង្រឹង និងអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវបទបញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ ។

**ទិន័យទី ៧**: ត្រូវពង្រឹងសវនកម្មនៅក្នុងការគ្រប់គ្រងថវិកា (ទាំងចំណូល- ទាំងចំណាយ) ទាំងអធិការកិច្ចហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ទាំងសវនកម្មផ្ទៃក្នុងនៃសាមីក្រសួង- ស្ថាប័ននីមួយៗ និង ទាំងសវនកម្ម ឯករាជ្យផ្ទៃក្រៅ ។

**ទិន័យទី ៨**: ហាមដាច់ខាតនូវការចុះកិច្ចសន្យានានាជាមួយក្រុមហ៊ុនឯកជន ដែលមានការពាក់ព័ន្ធដល់កាតព្វកិច្ចពន្ធដារ និង ចំណូល-ចំណាយរដ្ឋ ដោយមិនមានការចូលរួម និង ការឯកភាពពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ និង

**ទិន័យទី ៩**: ហាមដាច់ខាតនូវការខ្ចីឥណទាន ដែលមានលក្ខណៈពាណិជ្ជកម្ម ។

**ទិន័យទី ១០:** ត្រូវពង្រឹងគ្រប់គ្រងឱ្យបានហ្មត់ចត់បំផុតនូវទ្រព្យ-សម្បត្តិរបស់រដ្ឋគ្រប់ប្រភេទ ដោយគោរពយ៉ាងហ្មឹងម៉ាត់តាមច្បាប់ និងបទ-បញ្ញត្តិទាំងឡាយស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ។

រាជរដ្ឋាភិបាលយល់យ៉ាងច្បាស់ថា ការបង្កើនសន្សំយធនក្នុងស្រុក គឺជាកិច្ចការមួយដែលមានសារសំខាន់ខ្លាំងណាស់ សំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា ក្នុងអនាគតរយៈពេលវែង ។ ដើម្បីគោលដៅនេះ រាជរដ្ឋា-ភិបាលនឹងបន្តដាក់ចេញវិធានការពង្រឹងប្រព័ន្ធធនាគារក្នុងប្រទេស សំដៅធានាឱ្យបាននូវការគ្រប់គ្រងល្អប្រសើរ មានការត្រួតពិនិត្យហ្មត់ចត់ សម-ស្រប និង មានសមត្ថភាព និង ប្រសិទ្ធភាពគ្រប់គ្រាន់ ក្នុងការកៀងគរប្រាក់សន្សំយកមកផ្តល់ហិរញ្ញប្បទានសំរាប់ពង្រីកសកម្មភាពវិស័យឯកជន និងលើកកំពស់កំណើនសេដ្ឋកិច្ច ។ ជាចំណែកដ៏សំខាន់មួយនៃកិច្ចការនេះរាជរដ្ឋាភិបាលនឹងបន្តលើកស្ទួយវិស័យឥណទានជនបទ ដើម្បីជួយផ្តល់សេវាហិរញ្ញវត្ថុ និង ប្រាក់កម្ចីធ្វើដើមទុន ដែលមានការប្រាក់ទាបបំផុតតាមដែលអាចធ្វើបាន នៅក្នុងក្របខ័ណ្ឌនៃគោលការណ៍សេដ្ឋកិច្ចទីផ្សារ ដោយគិតគូរអំពីអត្រាការប្រាក់តាមវិស័យដូចគ្នា នៃប្រទេសជាសមាជិកអាស៊ានសំរាប់ជូនដល់ប្រជាពលរដ្ឋក្រីក្រ គ្រួសារដែលមានចំណូលទាប ព្រមទាំងសហគ្រាសធុនតូច និងមធ្យម ក្នុងទិសដៅជំរុញសកម្មភាពសេដ្ឋកិច្ចជនបទ និង រួមចំណែកលើកកំពស់ជីវភាពប្រជាពលរដ្ឋ នៅតាមមូលដ្ឋានឆ្ងាយដាច់ស្រយាល ។ បន្ថែមពីលើនេះ រាជរដ្ឋាភិបាលនឹងបង្កើនការយកចិត្តទុកដាក់ដល់ការរៀបចំប្រព័ន្ធច្បាប់ បទបញ្ជា និង យន្តការស្ថាប័នហិរញ្ញវត្ថុផ្សេងៗទៀត សំរាប់ប្រមែប្រមូលធនធានក្នុងស្រុក ដែលកំពុងតែស្ថិតនៅរាយប៉ាយ

នៅឡើយ តាមរយៈការបន្តធ្វើកំណែទម្រង់ និង សុក្រឹតកម្មប្រព័ន្ធពន្ធដារ ការពង្រឹងប្រព័ន្ធធនាគារពាណិជ្ជ និង វិស័យធានារ៉ាប់រង ការបង្កើតផ្សារមូលធន ។ល។ ស្របទៅតាម *«ចក្ខុវិស័យ និង ផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ សំរាប់ឆ្នាំ ២០០១-២០១០»* ដែលត្រូវបានរៀបចំឡើង នៅក្រោមជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និង ត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលនៅខែ សីហា ឆ្នាំ ២០០១ ។

### (ទី៤). សមាហរណកម្មកម្ពុជានៅក្នុងតំបន់ និង ពិភពលោក

រាជរដ្ឋាភិបាល នឹងបន្តជម្រុញការធ្វើសមាហរណកម្មប្រទេសកម្ពុជាទៅក្នុងសហគមន៍តំបន់ និង ពិភពលោក ដោយផ្តោតអាទិភាពជាពិសេសលើការខិតខំដើម្បីកាត់បន្ថយគម្លាតនៃការអភិវឌ្ឍន៍ ក្នុងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) តាមរយៈការចលនាបណ្តាប្រទេសជាសមាជិកអាស៊ាន និងប្រទេសជាដៃគូទាំងឡាយ ឱ្យចូលរួមយ៉ាងសកម្មក្នុងការអនុវត្តន៍គំរោងការនានានៃគំនិតផ្តួចផ្តើមសមាហរណកម្មអាស៊ាន ដែលបានអនុម័តក្នុងកិច្ចប្រជុំកំពូលអាស៊ានកន្លងមក ជាពិសេសវិធានការ និង គំរោងនានា ដែលបានអនុម័តនៅក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី ៨ កាលពី ខែវិច្ឆិកា ២០០២ នៅទីក្រុងភ្នំពេញ ។ ជាមួយគ្នានោះ រាជរដ្ឋាភិបាលនឹងបន្តចូលរួមយ៉ាងសកម្មក្នុងការអនុវត្តន៍ *«កម្មវិធីមហាអនុតំបន់មេគង្គ»* ពិសេសគំរោងអាទិភាពនានា ដែលបានអនុម័តនៅក្នុងកិច្ចប្រជុំកំពូលមហាអនុ-តំបន់មេគង្គ លើកទី ១ នៅទីក្រុងភ្នំពេញ នាខែ វិច្ឆិកា ២០០២ និងគំនិតផ្តួចផ្តើម *«តំបន់អភិវឌ្ឍន៍ត្រីកោណ»* កម្ពុជា-វៀតណាម-ឡាវ និងកម្ពុជា-ឡាវ-ថៃ និង *«យុទ្ធសាស្ត្រសហប្រតិបត្តិការសេដ្ឋកិច្ច»* រវាងកម្ពុជា

ឡាវ មីយ៉ាន់ម៉ារ និង ថៃ ។ ដើម្បីកម្ពុជាអាចទាញយកផលចំណេញពីសមាហរណកម្មអន្តរជាតិ យើងត្រូវពង្រឹងសមត្ថភាពស្ថាប័ន និង ដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រសហប្រតិបត្តិការជាមួយប្រទេសជិតខាង ដូចជា ការអនុវត្តទស្សនាទាន ***«ប្រទេសបួន-សេដ្ឋកិច្ចមួយ»*** ការបង្កើតតំបន់ត្រីកោណនៃកំណើនសេដ្ឋកិច្ច និង ការបង្កើតតំបន់សេរីសំរាប់កែច្នៃបំរើការនាំចេញ ។

បច្ចុប្បន្ននេះ ពិភពលោកទាំងមូលបានទទួលស្គាល់ថា ពាណិជ្ជកម្មសេរីអាចចូលរួមផ្តល់វិភាគទានយ៉ាងសំខាន់ ដល់ការកាត់បន្ថយភាពក្រីក្រ និង ការលើកកំពស់ជីវភាពរបស់ប្រជាជន ។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលនឹងបន្តដំណើរទៅមុខទៀតយ៉ាងស្វាហាប់ នៅលើមាគ៌ានៃការធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្ម សំដៅធានាឱ្យទំនិញ និង សេវាគ្រប់ប្រភេទអាចចរាចរបានដោយសេរីនៅក្នុងទូទាំងប្រទេស និង រវាងប្រទេសកម្ពុជា និង ប្រទេសជាដៃគូសំខាន់ៗនៅក្នុងតំបន់ និង លើសកលលោក ។ ការបើកច្រកឱ្យផលិតផលកម្ពុជាអាចឈានចូលដោយគ្មានរបាំង និង ឧបសគ្គនានា ទៅកាន់ទីផ្សារដ៏ធំធេងនៅក្នុងតំបន់ និង ក្នុងពិភពលោក នឹងផ្តល់ឱ្យកម្ពុជានូវកាលានុវត្តភាពនៃ «វិមាត្រសេដ្ឋកិច្ច» ដ៏វិសេសវិសាល ដែលនឹងផ្តល់ផលប្រយោជន៍ដល់សេដ្ឋកិច្ចកម្ពុជា ជាកំណើននៃការវិនិយោគ កំណើននៃការងារ កំណើននៃប្រាក់ចំណូល និង កំណើននៃសេដ្ឋកិច្ចជាតិទាំងមូល ដែលសុទ្ធតែជាកត្តាដ៏សំខាន់សំរាប់កាត់បន្ថយនូវភាពក្រីក្ររបស់ប្រជាជន ។ ក្នុងន័យនេះ ការចូលរួមរបស់កម្ពុជានៅក្នុងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន (AFTA) និង ការចូលជាសមាជិកក្នុងអង្គការពាណិជ្ជកម្មពិភពលោក

(WTO) នាពេលថ្មីៗនេះ គឺសុទ្ធតែជំហានដែលមានអត្ថន័យជាយុទ្ធសាស្ត្រ និង ជាប្រវត្តិសាស្ត្រ សំរាប់ការខិតខំប្រឹងប្រែងស្តារ និង អភិវឌ្ឍន៍កម្ពុជា ។

ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលនឹងប្រឹងប្រែងអនុវត្តយ៉ាងម៉ត់ចត់នូវកាតព្វកិច្ចរបស់កម្ពុជាជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក ។ ជាការពិត សមាជិកភាពនៅក្នុងអង្គការពាណិជ្ជកម្មពិភពលោកតម្រូវឱ្យមានការងារជាច្រើន ដូចជា ការអនុមតិ និង អនុវត្តន៍ច្បាប់ និង លិខិតបទដ្ឋាននីតិវិធីបាន់តំលៃ វិធីសាស្ត្របាន់តំលៃពាណិជ្ជកម្ម និង របាយការណ៍ដែលបាន់ប្រមាណផលប៉ះពាល់ដល់ការការពារពាណិជ្ជកម្ម ក៏ដូចជាការសិក្សាស្តីពីការផលិតស្រូវ ទីផ្សារកសិកម្មផ្សេងទៀត និង ដំណើរក្សេត្រវិទ្យាសិប្បកម្ម ទឹកស្អាត នេសាទ រោងចក្រ ទេសចរណ៍ និង សេវាពលកម្ម ដើម្បីទាញយកផលប្រយោជន៍ពីអង្គការនេះ ។ រាជរដ្ឋាភិបាលប្តេជ្ញាចិត្តយ៉ាងមុតមាំថា នឹងប្រើប្រាស់កាលានុវត្តភាពនេះ ដើម្បីកែទម្រង់ក្នុងគ្រប់វិស័យ ។

## ២ . ៣ . ចតុកោណយុទ្ធសាស្ត្រនាំចប្ចនសំរាប់ជម្រុញកំណើន

### ចតុកោណទី ១ . ការលើកស្ទួយវិស័យកសិកម្ម

***មុំទី១. ការលើកកំពស់ផលិតភាពកសិកម្ម និងពិពិធកម្មកសិកម្ម :***

ក្នុងនីតិកាលកន្លងមក រាជរដ្ឋាភិបាលសម្រេចបាននូវជោគជ័យគួរជាទីលើកទឹកចិត្តក្នុងការជម្រុញលើកកំពស់កំណើនសេដ្ឋកិច្ច។ ក៏ប៉ុន្តែ ទោះបីយ៉ាងណា កំណើននេះនៅមានមូលដ្ឋានតូចចង្អៀតនៅឡើយ ដោយសារវាពឹងផ្អែកជាសំខាន់ទៅលើវិស័យតែពីរប៉ុណ្ណោះ នោះគឺ ឧស្សាហកម្មកាត់-

ដេរ និង វិស័យទេសចរណ៍ ។ នេះ ជាប្រការដែលធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាមានលក្ខណៈងាយទទួលរងគ្រោះដោយសារអស្ថិរភាព និង វិបត្តិផ្សេងៗពីក្រៅប្រទេស ។ ក្នុងន័យនេះ យើងមានសេចក្ដីត្រូវការដ៏ចាំបាច់ ក្នុងការពង្រឹង និង ពង្រីកមូលដ្ឋាននៃកំណើនសេដ្ឋកិច្ចជាតិ ដោយប្រើប្រាស់សក្ដានុពលភាពសេដ្ឋកិច្ច ក្នុងវិស័យផ្សេងៗទៀតឱ្យបានកាន់តែច្រើន ពិសេសគឺវិស័យកសិកម្ម និង កសិ-ឧស្សាហកម្ម ដែលមានសក្ដានុពលកំណើនដ៏ធំធេង ហើយថែមទាំងអាចផ្ដល់ឥទ្ធិពលជាវិជ្ជមានយ៉ាងឆាប់រហ័ស ទៅលើកិច្ចខិតខំប្រឹងប្រែងរបស់យើង ដើម្បីលើកកំពស់ជីវភាពប្រជាជននៅតាមទីជនបទទៀតផង ។

គោលនយោបាយកសិកម្មរបស់រាជរដ្ឋាភិបាល គឺសំដៅលើកកំពស់ផលិតភាពកសិកម្ម និង ពិពិធកម្ម (Diversification) វិស័យកសិកម្មឱ្យក្លាយទៅជាផ្នែកនាំមុខមួយ ដែលអាចផ្ដល់ជីវភាពបន្ថែមដល់កំណើនសេដ្ឋកិច្ច និង អាចចូលរួមវិភាគទានយ៉ាងសំខាន់ដល់ការកាត់បន្ថយភាពក្រីក្រ ។ ក្នុងទិសដៅនេះ រាជរដ្ឋាភិបាលនឹងបង្កើនការប្រើប្រាស់ធនធានក្នុងស្រុកសំរាប់អនុវត្តពហុវប្បកម្ម និង ប្រពលវប្បកម្មកសិកម្ម ដើម្បីធានាបាននិរន្តរភាពនៃកំណើនសេដ្ឋកិច្ច បង្កើតការងារ និង បង្កើនប្រាក់ចំណូលនៅជនបទ ព្រមទាំងធានាសន្តិសុខស្បៀងសំរាប់ប្រជាជនទូទៅ ហើយធ្វើឱ្យប្រសើរឡើងនូវអាហារូបត្ថម្ភ និង បង្កើនការនាំចេញកសិផល ។ ក្នុងន័យនេះ ការបង្វែរទិសពីការអភិវឌ្ឍន៍តាមបែប ***«បើកទូលាយ»*** ឬ តាមបែប ***«វិបុលកម្ម»*** ទៅកាន់ការអភិវឌ្ឍន៍តាមបែប ***«ស៊ីជម្រៅ»*** ឬ តាមបែប ***«ប្រពលកម្ម»*** ពោលគឺ ការពង្រឹងសមត្ថភាពចិញ្ចឹមលើផ្ទៃដីដែលមានស្រាប់

តាមរយៈប្រពលកម្ម បានក្លាយទៅជាអាទិភាពដ៏ខ្ពស់បំផុតមួយរបស់រាជរដ្ឋាភិបាល ។

រាជរដ្ឋាភិបាលនឹងជម្រុញបង្កើតបរិយាកាសល្អ សំរាប់ការចូលរួមរបស់ផ្នែកឯកជន ដើម្បីការលូតលាស់នៃវិស័យកសិកម្ម តាមរយៈការប្រឹងប្រែងពន្លឿនការផ្តល់កម្មសិទ្ធិដីធ្លីនៅតាមតំបន់ជនបទ ក្នុងទិសដៅពង្រឹងសុវត្ថិភាពនៃការកាន់កាប់ដីធ្លីកសិកម្ម ការពង្រីក និង បែងចែកដីធ្លីកសិកម្មក្នុងក្របខ័ណ្ឌដីសម្បទានសង្គមកិច្ច ការអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រពផ្ទៃដី និង ការគ្រប់គ្រងធនធានទឹក ដោយយកចិត្តទុកដាក់ផងដែរ ដល់ការបង្កើនប្រសិទ្ធភាពក្នុងការប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រដែលមានស្រាប់ ការបន្តបង្កើត និងពង្រឹងគុណភាពសហគមន៍អ្នកប្រើប្រាស់ទឹក ព្រមទាំងការកាត់បន្ថយភាពងាយរងគ្រោះពីគ្រោះធម្មជាតិ និង ការពឹងផ្អែកទាំងស្រុងលើលក្ខខណ្ឌធម្មជាតិ ។ល។

ក្នុងទិសដៅជម្រុញផលិតភាពកសិកម្ម រាជរដ្ឋាភិបាលនឹងយកចិត្តទុកដាក់បន្ថែមទៀត ចំពោះការពង្រីកសេវាកម្មគាំទ្រដល់វិស័យនេះ ដូចជាការងារស្រាវជ្រាវ និង ផ្សព្វផ្សាយ ការអភិវឌ្ឍន៍ទីផ្សារកសិកម្ម ការបែងចែកសំភារៈ ពូជ ជី និង ការផ្តល់ឥណទានជនបទ ។ល។ ក្នុងក្របខ័ណ្ឌនេះ រាជរដ្ឋាភិបាលនឹងផ្តល់អាទិភាពជាពិសេស ទៅលើការតម្រង់ទិសកិច្ចការវិនិយោគសាធារណៈ និង ការលើកទឹកចិត្តវិនិយោគឯកជន ឱ្យឆ្ពោះទៅរកវិស័យកសិកម្ម សំដៅការលើកកំពស់កំណើនកសិផល និង ធានាគុណភាពកសិផលកម្ពុជា ឱ្យឆ្លើយតបទៅនឹងការតម្រូវនៃស្តង់ដារអន្តរជាតិ ។

រាជរដ្ឋាភិបាលបន្តផ្ដល់អាទិភាព ទៅលើកិច្ចការអភិវឌ្ឍន៍តំបន់ព្រំដែន និង តំបន់ជនបទដាច់ស្រយាល ដើម្បីទប់ស្កាត់ការធ្វើចំណាកចោលស្រុក តាមរយៈការរៀបចំ និង កសាងតំបន់ទីប្រជុំជនមួយចំនួន ដែលមានបណ្ដាញហេដ្ឋារចនាសម្ព័ន្ធសមស្រប សំរាប់សម្រួលដល់ជីវភាពរស់នៅ និង ការចូលរួមទៅក្នុងសកម្មភាពសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋនៅទីនោះ ។

រាជរដ្ឋាភិបាលបន្តជម្រុញចលនា ***«ភូមិមួយ-ផលិតផលមួយ»*** ដើម្បីលើកស្ទួយគំនិតច្នៃប្រឌិត និង ជំនឿលើខ្លួនឯងរបស់ប្រជាពលរដ្ឋនៅតាមទីជនបទ ដោយឈរលើគោលការណ៍សំខាន់ៗបួនយ៉ាងគឺៈ (ទី១). ការរិះរកវិធីផលិត ដែលសមស្របទៅនឹងស្ថានភាពជាក់ស្ដែងនៃបរិស្ថានភូមិឋាន និង សមស្របទៅតាមសេចក្ដីត្រូវការរបស់ទីផ្សារ (ទី២). ការបង្កលក្ខណៈងាយស្រួល និង ការផ្ដល់ការលើកទឹកចិត្តប្រជាពលរដ្ឋក្នុងការផលិត ដូចជា ការស្វែងរកទីផ្សារ ការផ្ដល់ឥណទាន ការផ្ទេរបច្ចេកវិទ្យា និង ការផ្ដល់ពូជ (ទី៣). ការជួយបណ្ដុះបណ្ដាលសមត្ថភាពគ្រប់គ្រង និង ធនធានមនុស្ស និង (ទី៤). ការបង្កលក្ខណៈងាយស្រួល ឱ្យប្រជាពលរដ្ឋបង្កើតសហគមន៍កសិកម្ម ក្នុងទិសដៅធានាតម្លៃផលិតផល ។

***មុំទី២. កំណែទម្រង់ដីធ្លី និង ការបោសសំអាតមីន :***

ដី និង ទឹក គឺជាធនធានធម្មជាតិសំខាន់ពីរជាមូលដ្ឋាន ដែលអាចយកមកប្រើប្រាស់សំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និង កាត់បន្ថយភាពក្រីក្រ ជាពិសេសនៅតំបន់ជនបទ ។ ដោយបន្តអនុវត្តច្បាប់ភូមិបាល និង គោលនយោបាយដីធ្លី រាជរដ្ឋាភិបាលប្រមូលផ្តុំជាសំខាន់លើវិធានការពង្រឹងប្រព័ន្ធគ្រប់គ្រង បែងចែក និងប្រើប្រាស់ដីធ្លីប្រកបដោយសមធម៌ និង

ដោយធានាបាននូវប្រសិទ្ធភាពសេដ្ឋកិច្ច តាមរយៈការចុះបញ្ជីដីធ្លី ការបែងចែកដីធ្លី ការធានាសុវត្ថិភាពនៃកម្មសិទ្ធិលើដីធ្លី ការលុបបំបាត់ភាពអនាធិបតេយ្យ ក្នុងការកាន់កាប់ដីដោយខុសច្បាប់ ការដាក់ចេញវិធានការសមស្រប ដើម្បីទប់ស្កាត់ការប្រមូលដីទុកដោយមិនប្រើប្រាស់ មិនធ្វើផលិតកម្ម ឬ អាជីវកម្ម ។ល។ រាជរដ្ឋាភិបាលពិនិត្យឡើងវិញនូវដីទំនេររបស់រដ្ឋ ឬ ដីរដ្ឋដែលឯកជនកាន់កាប់ ដោយមិនស្របតាមលិខិតបទដ្ឋានគតិយុត្ត និង នីតិវិធីដែលបានកំណត់កន្លងមក ។ រាជរដ្ឋាភិបាលនឹងបន្តផ្តល់អាទិភាពដល់ការពង្រឹងសិទ្ធិកាន់កាប់ដីធ្លីជូនប្រជាពលរដ្ឋ ដែលត្រូវការដីសំរាប់សង់លំនៅដ្ឋាន និង ធ្វើអាជីវកម្មកសិកម្មជាគ្រួសារ ក្នុងក្របខណ្ឌដីសម្បទានដើម្បីគោលដៅសង្គមកិច្ច ដោយឈរលើគោលការណ៍ជួយគ្រួសារក្រីក្រ និង ក្រុមជនងាយរងគ្រោះ ។

រាជរដ្ឋាភិបាលយល់ច្បាស់ថា ការបោសសំអាតមីនមិនមែនគ្រាន់តែជាបញ្ហាសន្តិសុខមួយមុខប៉ុណ្ណោះទេ ប៉ុន្តែ វាពាក់ព័ន្ធទៅនឹងបញ្ហាសេដ្ឋកិច្ច និង ការអភិវឌ្ឍន៍ជារួម ជាពិសេសបញ្ហាការផ្គត់ផ្គង់ដី និងការផ្តល់សុវត្ថិភាពក្នុងការប្រកបអាជីវកម្មនៃគ្រួសារកសិករក្រីក្រ នៅទីជនបទដាច់ស្រយាល ។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលនឹងអនុវត្តការងារតាមនីតិវិធី ដែលបានរៀបចំដើម្បីធានាសកម្មភាពកម្ចាត់មីន ដែលកំពុងអនុវត្តនៅកម្ពុជាឱ្យមានសុវត្ថិភាព មានការសម្របសម្រួល និង មានផែនការល្អ និង អនុវត្តតាមស្តង់ដារជាតិ និង កាតព្វកិច្ចអន្តរជាតិ ។

*មុំទី៣. កំណែទម្រង់វិស័យនេសាទ និង ជលផល :*

មច្ឆជាតិមានសារសំខាន់ជាអាយុជីវិត សំរាប់ប្រជាជនកម្ពុជារាប់លាននាក់ ដោយផ្តល់ជាស្បៀងអាហារ ជាចំណូល និង ការរស់នៅ ហើយគួបផ្សំនឹងអង្ករ ត្រីដែលជាផ្នែកមួយសំខាន់នៃសន្តិសុខស្បៀង បានផ្តល់ប្រូតេអ៊ីនចំនួនបីភាគបួនដល់ប្រជាជនចំនួន ២ លាននាក់ ។ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការអភិវឌ្ឍន៍វិស័យជលផលប្រកបដោយចិរភាព និង មានសមធម៌ ដោយប្រគល់សិទ្ធិអំណាចទៅឱ្យសហគមន៍ជនបទ ដើម្បីឱ្យប្រជាកសិករអាចចូលរួមបានយ៉ាងសកម្ម ក្នុងការរៀបចំផែនការ និង កម្មវិធីនានា ហើយទទួលខុសត្រូវគ្រប់គ្រងធនធានជលផលដោយខ្លួនឯង ។

រាជរដ្ឋាភិបាលនឹងបង្វែរឡូត៍នេសាទចប់កិច្ចសន្យាមួយចំនួន ទុកជាកន្លែងអភិរក្សពូជត្រី សំរាប់បង្កើនផលស្តុកធម្មជាតិផង និងរក្សាពូជត្រីដែលស្ទើរផុតពូជឱ្យកើតមានសម្បូរឡើងវិញផង ព្រមទាំងជម្រុញបង្កើនទំហំដែននេសាទសំរាប់ជូនប្រជាពលរដ្ឋប្រើប្រាស់ និង ជម្រុញការអភិវឌ្ឍន៍ផ្នែកវារីវប្បកម្ម ដើម្បីឆ្លើយតបទៅនឹងតំរូវការសាច់ត្រីកើនឡើងផង ព្រមទាំងបន្ថយសម្ពាធលើធនធានជលផលធម្មជាតិផងដែរ ។

*មុំទី៤. កំណែទម្រង់ព្រៃឈើ :*

គោលដៅនៃយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល នៅក្នុងវិស័យព្រៃឈើគឺធានាឱ្យបាននូវការគ្រប់គ្រងព្រៃឈើប្រកបដោយចិរភាព ដោយឈរលើមូលដ្ឋាននៃសសរទ្រូងបីសំខាន់ៗ÷

ទី១. គោលនយោបាយគ្រប់គ្រងព្រៃឈើ ប្រកបដោយចិរភាព ដោយមានការត្រួតពិនិត្យអាជីវកម្មព្រៃឈើយ៉ាងហ្មឹងម៉ាត់ និង សមស្រប តាមនិយាមនៃការគ្រប់គ្រងព្រៃឈើជាអន្តរជាតិ ដែលតម្រូវឱ្យមានទំហំព្រៃឈើបម្រុងទុកគ្រប់គ្រាន់សំរាប់ទប់ទល់ការប្រើប្រាស់របស់ប្រជាពលរដ្ឋ និង សំរាប់ការពារភាពរាំងស្ងួត និង ទឹកជំនន់ ព្រមទាំងមានព្រៃលិចទឹកសំរាប់ទុកជាជម្រកមច្ឆជាតិ ។

ទី២ . ប្រព័ន្ធការពារធនធានធម្មជាតិ ដើម្បីធ្វើការអភិរក្សជីវសាស្ត្រចម្រុះ និង ប្រភេទដែលកម្រ ។

ទី៣. ការអនុវត្តន៍កម្មវិធីអភិវឌ្ឍន៍សហគមន៍ព្រៃឈើមួយ ដែលរឹងមាំ មានតម្លាភាព និង មានការគ្រប់គ្រងដោយផ្ទាល់របស់ប្រជាពលរដ្ឋ ក្នុងតំបន់នោះ ។

រាជរដ្ឋាភិបាលបានផ្អាក និង ពិនិត្យអាជីវកម្មព្រៃឈើសម្បទានដែលនៅសេសសល់ទាំងអស់ឡើងវិញ ដើម្បីវាយតម្លៃស្ថានភាពបច្ចុប្បន្នសំដៅទៅលើការគ្រប់គ្រងឱ្យមានប្រសិទ្ធភាព ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលនឹងបន្តជម្រុញគោលនយោបាយដាំដុះព្រៃឈើឡើងវិញ ។

## ចតុកោណទី ២. ការបន្តស្តារ និង កសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

### *មុំទី១. ការបន្តស្តារ និង កសាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ :*

បណ្តាញគមនាគមន៍មានតួនាទីជាសរសៃឈាម សំរាប់តភ្ជាប់គ្រប់ច្រកល្ហកនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្លាយទៅជាសរីរាង្គកាយសេដ្ឋកិច្ច

មួយ ដែលធានាបាននូវសមាហរណកម្មផ្ទៃក្នុងខ្លួនឯងផង និង សមាហរណកម្មសេដ្ឋកិច្ចកម្ពុជាជារូបវន្ត ទៅក្នុងសេដ្ឋកិច្ចតំបន់ និង ពិភពលោកផង ។ លើសពីនេះទៀត សំរាប់ស្ថានភាពសេដ្ឋកិច្ចកម្ពុជា ហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៅមានតួនាទីដ៏សំខាន់ជា *«ក្បាលរថភ្លើងនៃកំណើនសេដ្ឋកិច្ច»* និង ជាមធ្យោបាយដ៏មានប្រសិទ្ធភាពបំផុតមួយ សំរាប់កាត់បន្ថយភាពក្រីក្រ និង ទុក្ខលំបាកវេទនារបស់ប្រជាជន ។

នៅលើមូលដ្ឋាននៃទស្សនៈវិជ្ជានេះ រាជរដ្ឋាភិបាលនឹងបន្តផ្តល់អាទិភាពខ្ពស់ទៅលើការស្តារ និង កសាងប្រព័ន្ធគមនាគមន៍ដឹកជញ្ជូនគ្រប់ប្រភេទ រួមមាន ថ្នល់- ស្ពាន ផ្លូវដែក ផ្លូវទឹក កំពង់ផែ និងអាកាសយានដ្ឋាន ដែលតភ្ជាប់រវាងគ្រប់តំបន់នៅទូទាំងប្រទេស ទាំងទីក្រុង ទីប្រជុំជន និង តំបន់ជនបទឆ្ងាយដាច់ស្រយាល និង តភ្ជាប់ជាមួយបណ្តាប្រទេសជិតខាង ឱ្យទៅជាប្រពន្ធ័គមនាគមន៍ដឹកជញ្ជូនមួយដ៏ងាយស្រួល មានស្ថិរភាព មានសុវត្ថិភាព មានប្រសិទ្ធភាពសេដ្ឋកិច្ច និងមានតម្លៃទាប ក្នុងទិសដៅសម្រួលដល់ការធ្វើពាណិជ្ជកម្ម ជម្រុញវិស័យទេសចរណ៍ ការអភិវឌ្ឍន៍ជនបទ ការធ្វើសមាហរណកម្មសេដ្ឋកិច្ចទៅក្នុងតំបន់ និង ក្នុងសកលលោក ពិសេសគឺបំរើដល់កិច្ចការពារជាតិថែមទៀត ។ ក្នុងនេះ អាទិភាពខ្ពស់ នឹងត្រូវបានផ្តោតទៅលើការបន្តកសាងផ្លូវជនបទ ជាមួយនឹងការពង្រឹងវិធានការថែទាំផ្លូវថ្នល់ ដើម្បីរក្សាស្ថិរភាពនៃការដឹកជញ្ជូន និង ការធ្វើដំណើរ ។

រាជរដ្ឋាភិបាលនឹងខិតខំពុះពារបន្តកិច្ចការស្តារ និងអភិវឌ្ឍបណ្តាញផ្លូវដែក និង ជម្រុញការប្រើប្រាស់ផ្លូវដែកសំរាប់ការដឹកជញ្ជូនធុនធ្ងន់ ។ វិស័យអាកាសចរណ៍ស៊ីវិលនឹងត្រូវបានលើកកំពស់ថែមទៀត ក្នុងទិសដៅ

ធានាឱ្យសេវាអាកាសចរណ៍ស៊ីវិល  អាចចូលរួមយ៉ាងសកម្ម  ក្នុងការលើកស្ទួយកំណើនសេដ្ឋកិច្ចជាតិ ជាពិសេសគឺវិស័យទេសចរណ៍ជាតិ ។

### *មុំទី២. ការគ្រប់គ្រងធនធានទឹក និង ប្រព័ន្ធធារាសាស្ត្រ*

គោលនយោបាយធនធានទឹក  គឺជាផ្នែកមួយនៃគំរោងទូលំទូលាយ ដែលផ្តល់ជាមូលដ្ឋានដល់ការការពារ ការគ្រប់គ្រង និង ការប្រើប្រាស់ទឹកសាប ទឹកប្រៃ និង ធនធានទឹកសមុទ្រ ឱ្យមានលក្ខណៈចិរភាព ស្មើភាព និង បំរើផលប្រយោជន៍សាធារណៈឱ្យមានប្រសិទ្ធភាព ។ ទិសដៅរបស់គោល-នយោបាយនេះ គឺប្រមើលមើលជាមុន និង ដោះស្រាយរាល់បញ្ហា ដែលស្ថាប័នបំពេញការងារក្នុងវិស័យទឹកប្រឈមមុខក្នុងកំឡុងពេល ២០ ឆ្នាំខាងមុខ ហើយជួយវិស័យនេះ ឱ្យប្រកាន់យកវិធានការសមស្របដើម្បីដោះ-ស្រាយបញ្ហាទាំងអស់នេះ ។

អនុវត្តស្មារតីនេះ រាជរដ្ឋាភិបាលនឹងផ្តោតការយកចិត្តទុកដាក់លើៈ (១). ការផ្តល់ឱ្យពលរដ្ឋគ្រប់រូបនូវទឹក ដែលមានសុវត្ថិភាព និង ប្រកបដោយអនាម័យ (២). ការផ្តល់សេរីភាពដល់ពលរដ្ឋគ្រប់រូប ដោយបញ្ចៀសការគំរាមកំហែងបាត់បង់ជីវិត និង លក្ខខណ្ឌជីវិត ដែលបណ្តាលមកពីភាពចៃដន្យដែលទាក់ទងនឹងទឹក (៣). ការផ្តល់ទឹកគ្រប់គ្រាន់ដល់កន្លែងណាដែលត្រូវការ ដើម្បីធានាបាននូវសន្តិសុខស្បៀង សំរាប់ការរស់នៅរបស់ប្រជាជន និង សំរាប់សកម្មភាពសេដ្ឋកិច្ច (៤). ការធានាបរិស្ថានទឹកដែលគ្មានជាតិពុល និង ការទ្រទ្រង់ជីវិតមច្ឆា និងប្រព័ន្ធអេកូឡូស៊ីនៅក្នុងទឹក ។

រាជរដ្ឋាភិបាលនឹងបន្តអភិវឌ្ឍប្រព័ន្ធស្រោចស្រពផ្ទៃដី និង ការគ្រប់គ្រងធនធានទឹក ដោយផ្តោតការយកចិត្តទុកដាក់លើការបង្កើនប្រសិទ្ធភាព

ក្នុងការប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រដែលមានស្រាប់ ការបន្តបង្កើត និង ពង្រឹងគុណភាពសហគមន៍អ្នកប្រើប្រាស់ទឹក និង ការកាត់បន្ថយភាពងាយរងគ្រោះពីគ្រោះធម្មជាតិ និង ការពឹងផ្អែកទាំងស្រុងលើលក្ខខណ្ឌធម្មជាតិ ។

***មុំទី៣. ការអភិវឌ្ឍន៍វិស័យថាមពល និង បណ្តាញអគ្គិសនី:***

ការបន្តអភិវឌ្ឍវិស័យថាមពល ដើម្បីធានាឆ្លើយតបប្រកបដោយប្រសិទ្ធភាព និង ក្នុងថ្លៃថោកសមរម្យ ទៅនឹងតម្រូវការនៃការប្រើប្រាស់ដែលចេះតែកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ គឺជារបៀបវារៈដ៏សំខាន់បំផុតមួយនៃគោលនយោបាយសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល ។ ក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលនឹងផ្តល់អាទិភាពខ្ពស់ ទៅលើការទាក់ទាញឱ្យមានការចូលរួមរបស់ផ្នែកឯកជននៅក្នុងការផលិតផ្គត់ផ្គង់អគ្គិសនី ពិសេសនៅតាមបណ្តាទីរួមខេត្ត និងទីប្រជុំជនសំខាន់ៗ ការអនុវត្តន៍គម្រោងអគ្គិសនីភាវូបនីយកម្មតំបន់ជនបទប្រកបដោយគុណភាព និង មានតំលៃទាបសមរម្យ ព្រមទាំងគម្រោងតភ្ជាប់ខ្សែបញ្ជូនថាមពលពីប្រទេសជិតខាង ។

ការស្តារ និង ពង្រីកប្រព័ន្ធផ្គត់ផ្គង់សមត្ថភាពផលិតកម្មអគ្គិសនីនៅភ្នំពេញ កំពុងតែត្រូវបានបន្តអនុវត្ត តាមរយៈការនាំចូលអគ្គិសនីពីប្រទេសជិតខាង និង គម្រោងការសាងសង់រោងចក្រអគ្គិសនីដោយចំហាយ តាមតំបន់មាត់សមុទ្រ ។ នៅក្នុងផ្នែកហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី រាជរដ្ឋាភិបាលមានផែនការអភិវឌ្ឍថាមពលវារីអគ្គិសនីកំចាយ ស្ទឹងបាត់ដំបង ស្ទឹងអាតាយ និង ស្ទឹងឬស្សីជ្រុំ ។ ទន្ទឹមនឹងនេះ ក្នុងការអភិវឌ្ឍន៍ផ្នែកវារីអគ្គិសនី រាជរដ្ឋាភិបាលមិនត្រឹមតែគិតគូរពីបញ្ហាបរិស្ថានធម្មជាតិ និង សង្គមប៉ុណ្ណោះទេ ប៉ុន្តែ ក៏គិតគូរផងដែរអំពីបញ្ហាសេដ្ឋកិច្ច ។

### មុំទី៤. ការអភិវឌ្ឍន៍បច្ចេកវិទ្យាពត៌មាន និង ទូរគមនាគមន៍៖

គោលនយោបាយ និង យុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ក្នុងវិស័យនេះ គឺបន្តអភិវឌ្ឍប្រព័ន្ធប្រៃសណីយ៍ និង ទូរគមនាគមន៍ និង ជម្រុញការ-អភិវឌ្ឍន៍បច្ចេកវិទ្យាពិតមាន ប្រកបដោយគុណភាពខ្ពស់ ស្របតាមស្តង់ដារអន្តរជាតិ មានថ្លៃថោកសមរម្យ និង មានសេវាកម្មទំនើបគ្របដណ្តប់ទូទាំងប្រទេស តាមរយៈការអនុវត្តន៍វិធានការដូចតទៅ៖

- បន្តជម្រុញការវិនិយោគ ទៅលើបណ្តាញហេដ្ឋារចនាសម្ព័ន្ធឆ្អឹងខ្នង (Backbone infrastructure) សំរាប់បំរើឱ្យវិស័យបច្ចេកវិទ្យាពត៌មាន និង ទូរគមនាគមន៍ (Information and Comunication Technology--ICT) ពិសេសបណ្តាញខ្សែកាបអុបទិចដែលមានសមត្ថភាពខ្ពស់ ដែលនឹងចូលរួមបំរើប្រកបដោយប្រសិទ្ធភាពផងដែរ ដល់បណ្តាញទូរគមនាគមន៍ជនបទ ។

- បង្កើតឱ្យមានបណ្តាញទូរគមនាគមន៍នៅក្រុងភ្នំពេញ ក្រុងព្រះ-សីហនុ និង ក្រុងសៀមរាប និង ពង្រីកសេវាកម្ម នៅតាមក្រុង និង ទីរួមខេត្ត ។

- ដាក់ចេញនូវបទដ្ឋានថ្នាក់ជាតិ សំរាប់ការរៀបចំគម្រោងការសាងសង់ និង កិច្ចប្រតិបត្តិការគ្រប់សេវាទូរគមនាគមន៍ និង សំរាប់បច្ចេកវិទ្យាពត៌មាន រួមមានប្រព័ន្ធស្តង់ដារ និងបទដ្ឋានសំរាប់ការប្រើប្រាស់បច្ចេកវិទ្យាកុំព្យូទ័រ និង អ៊ីនទែរណិតផងដែរ ។

-ពង្រឹងឱ្យបានរឹងមាំនូវរចនាសម្ព័ន្ធប្រៃសណីយ៍ ព្រមទាំងសមត្ថភាពស្ថាប័ន ដើម្បីធ្វើឱ្យសេវាកម្មលើកិច្ចការនេះ មានការរីកចំរើនប្រសើរឡើង ។

-ពង្រីកបណ្តាញផ្សព្វផ្សាយតាមវិទ្យុ និង ទូរទស្សន៍ ក្នុងគោលដៅបង្កើនប្រសិទ្ធភាព និងសម្រួលដល់ការធ្វើសេវាលើផ្នែកពតិមាន និងកិច្ចការប្រៃសណីយ៍ ។

ក្នុងរយៈពេល ៥ ឆ្នាំខាងមុខ រាជរដ្ឋាភិបាលប្តេជ្ញាបង្កើត និងពង្រីកឱ្យបានទូលាយ នូវបណ្តាញទំនាក់ទំនងទូរសព្ទ័សំរាប់អតិថិជននៅភ្នំពេញ និង បង្កើតឱ្យមានទំនាក់ទំនងតាមរលកជាតុអាកាសកំរិតទាប (Micro-wave) ឬទំនាក់ទំនងតាមខ្សែកាប្លអុបទិច ដោយតភ្ជាប់ៈ (១). កំពង់ចាម-ភ្នំពេញ- តាកែវ- កំពត- ក្រុងព្រះសីហនុ (២). កំពង់ចាម- កំពង់ធំ-សៀមរាប- ស៊ីសុផុន (៣). កំពង់ចាម- ក្រចេះ- ស្ទឹងត្រែង និង (៤). មណ្ឌលគីរី- ប៉ៃលិន- ព្រះវិហារ- ឧត្តរមានជ័យ ។

រាជរដ្ឋាភិបាល នឹងជម្រុញអនុវត្តគោលនយោបាយបើកទូលាយវិស័យបច្ចេកវិទ្យាពតិមាន និង ទូរគមនាគមន៍ សំរាប់ការចូលរួមរបស់វិស័យឯកជន ដោយគ្មានការរើសអើង ដោយឈរលើមូលដ្ឋាននៃការប្តេជ្ញាចិត្ត និង កាពតួកិច្ចទាំងឡាយរបស់កម្ពុជានៅក្នុងក្របខ័ណ្ឌនៃអង្គការពាណិជ្ជកម្មពិភពលោក ។

## ចតុកោណទី៣. ការអភិវឌ្ឍផ្នែកឯកជន និង ការងារ

### *មុំទី១. ការពង្រឹងវិស័យឯកជន និង ការទាក់ទាញការវិនិយោគ:*

រាជរដ្ឋាភិបាលចាត់ទុកវិស័យឯកជន ជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ច ហើយរាជរដ្ឋាភិបាលជាអ្នករៀបចំយុទ្ធសាស្ត្រដើម្បីបង្កើតបរិស្ថានធុរកិច្ចឱ្យកាន់តែប្រសើរសំរាប់វិស័យឯកជន និង ជាអ្នកគ្រប់គ្រងការអភិវឌ្ឍន៍ ។ វិស័យឯកជនដ៏រឹងមាំ គឺជាគន្លឹះសំរាប់ជម្រុញការអភិវឌ្ឍន៍សេដ្ឋកិច្ច ដូច្នេះ រាជរដ្ឋាភិបាលនឹងបន្តកិច្ចខិតខំប្រឹងប្រែង ដើម្បីបើកច្រកចូលទៅកាន់ទីផ្សារអន្តរជាតិដ៏ធំទូលាយ តាមរយៈការអនុវត្តន៍គោលនយោបាយសមាហរណកម្មសេដ្ឋកិច្ចកម្ពុជា ទៅក្នុងសេដ្ឋកិច្ចតំបន់ និងពិភពលោក ការជម្រុញអនុវត្តយ៉ាងសកម្មនូវការងារស្តារ និង អភិវឌ្ឍប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធជាតិ ទាំងផ្នែករឹង ទាំងផ្នែកទន់ ការបន្តពង្រឹងក្របខ័ណ្ឌច្បាប់ ព្រមទាំងបទបញ្ញត្តិ និង សមត្ថភាពស្ថាប័ន ដែលសម្រួលដល់សកម្មភាពធុរកិច្ចពាណិជ្ជកម្ម និង ការវិនិយោគទុនឯកជន ជាពិសេសសំរាប់ការប្រកួតប្រជែងដោយយុត្តិធម៌ តម្លាភាព គណនេយ្យភាព និង សំរាប់ភាពជាដៃគូប្រកបដោយផ្លែផ្ការវាងវិស័យឯកជនជាមួយនឹងវិស័យសាធារណៈ ។ អាទិភាពពិសេសក្នុងនីតិកាល ទី ៣ នេះ នឹងត្រូវផ្តោតទៅលើការរៀបចំឱ្យកាន់តែប្រសើរឡើងនូវបរិស្ថានរួមសំរាប់ការអភិវឌ្ឍន៍វិស័យឯកជន តាមរយៈវិធានការជាក់ស្តែងនានាដែលសំដៅ (១). ពង្រឹងអភិបាលកិច្ចទាំងក្នុងវិស័យសាធារណៈ (Public Governance) ទាំងក្នុងវិស័យឯកជន (Corporate Governance) (២). សម្រួលពាណិជ្ជកម្ម និង កែលំអបរិយា-

កាសវិនិយោគ និង (៣). ជម្រុញអភិវឌ្ឍធនធានមនុស្សឱ្យឆ្លើយតបប្រកប ដោយប្រសិទ្ធភាព ទៅនឹងតម្រូវការនៃទីផ្សារ ។

នៅក្នុងនីតិកាលថ្មីនេះ រាជរដ្ឋាភិបាលនឹងបន្តផ្ដោតការយកចិត្តទុក ដាក់លើការទាក់ទាញការចូលរួមរបស់វិស័យឯកជន នៅតាមវិស័យអាទិភាព ទាំង ៦ យ៉ាង ដែលបានកំណត់កន្លងមក គឺ ÷

១- ការអភិវឌ្ឍន៍វិស័យកសិកម្ម និង កសិ-ឧស្សាហកម្ម ក្នុងនោះ ផ្តល់អាទិភាពលើការដោះស្រាយទឹកសំរាប់កសិកម្ម ។

២- ការអភិវឌ្ឍន៍ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ដឹកជញ្ជូន និង ទូរគមនាគមន៍

៣- ការអភិវឌ្ឍន៍វិស័យថាមពល និង អគ្គិសនី

៤-វិស័យឧស្សាហកម្មអតិពលកម្ម និងឧស្សាហកម្មកែច្នៃសំរាប់ការ នាំចេញ

៥-វិស័យឧស្សាហកម្មទេសចរណ៍ និង

៦- ការអភិវឌ្ឍន៍ធនធានមនុស្ស ។

*មុំទី២. ការលើកស្ទួយសហគ្រាសធុនតូច និង មធ្យមៈ*

រាជរដ្ឋាភិបាល បានលើកទិសដៅជំរុញការអភិវឌ្ឍន៍សហគ្រាសធុន តូច និង មធ្យម (SME) ដោយបានកំណត់គោលនយោបាយដូចតទៅ៖ (១). លើកទឹកចិត្តដល់ការរីកលូតលាស់សហគ្រាសធុនតូច និង មធ្យម ជា ពិសេស តាមរយៈការផ្តល់ឥណទានរយៈពេលមធ្យម និង រយៈពេលវែង (២). ទប់ស្កាត់ការរត់គេចពន្ធគ្រប់ប្រភេទ (៣). កាត់បន្ថយបែបបទសំរាប់ ការចុះបញ្ជី និង ការរៀបចំដំណើរការក្រុមហ៊ុន (៤). សម្រួលដល់ការ-

នាំចេញ- នាំចូល តាមរយៈការកាត់បន្ថយបែបបទស្មុគ្រស្មាញ មានដូចជា អាជ្ញាប័ណ្ណ និង លិខិតអនុញ្ញាតផ្សេងៗ ។ល។ (៥). ផ្តល់ការគាំពារដល់ឧស្សាហកម្មក្មេងខ្ចីមួយចំនួន ក្នុងរយៈពេលសមស្របមួយ (៦). ជម្រុញសម្ព័ន្ធភាពរវាងសហគ្រាសខ្នាតតូច និង មធ្យម ជាមួយនឹងឧស្សាហកម្មធុនធំ (៧). ជម្រុញបង្កើតមជ្ឈមណ្ឌលផលិតភាពជាតិ ដែលជួយដល់ឧស្សាហកម្មធុនតូច និង មធ្យម តាមរយៈការលើកកំពស់ផលិតភាព និង ការកាត់បន្ថយថ្លៃដើមនៃផលិតកម្ម (៨). បង្កើតវិទ្យាស្ថានស្តង់ដារជាតិ ដែលនឹងជួយធានាឱ្យគុណភាពផលិតផលក្នុងប្រទេស អាចឆ្លើយតបបានទៅនឹងស្តង់ដារតំបន់ និង អន្តរជាតិ (៩). បង្កើតមន្ទីរពិសោធន៍ជាតិផ្នែករូបគីមី មីក្រូជីវៈ មេកានិច និង ការធ្វើតេស្ត ដែលអាចកំណត់បានលើគុណភាព និង លក្ខណៈវិនិច្ឆ័យរបស់ផលិតផល (១០). ពង្រឹងយន្តការការពារកម្មសិទ្ធិបញ្ញាឧស្សាហកម្ម ដែលការពារដល់ការលួចចម្លងដោយខុសច្បាប់ ក្នុងការរិះរក និង ប្រើប្រាស់បច្ចេកទេស និង បច្ចេកវិទ្យាថ្មី ព្រមទាំងផលិតផលថ្មី (១១). ជម្រុញដល់ការបណ្តុះបណ្តាលមុខវិជ្ជាជំនាញ ទាំងនៅក្នុង និង ក្រៅប្រទេស (១២). បង្កើនចលនាចំនួនភូមិមួយផលិតផលមួយ និង (១៣). ពង្រឹងប្រព័ន្ធច្បាប់ ដោយបង្កើតច្បាប់រោងចក្រ ច្បាប់តំបន់ឧស្សាហកម្ម ច្បាប់ប៉ាតង់ និង តក្កកម្មឧស្សាហកម្ម ច្បាប់រង្វាស់រង្វាល់ ច្បាប់សុវត្ថិភាពឧស្សាហកម្ម ។ល។

### *មុំទី៣. ការបង្កើតការងារ និងការធានាលក្ខខណ្ឌការងារល្អប្រសើរ ជូនកម្មករ និង និយោជិតៈ*

រាជរដ្ឋាភិបាលនឹងជម្រុញអនុវត្តគោលនយោបាយជាប្រព័ន្ធ និងជាខ្សែសង្វាក់ សំដៅបង្កើតការងារឱ្យបានច្រើនជូនដល់ស្រទាប់យុវវ័យ ដែលដល់អាយុឈានចូលក្នុងទីផ្សារពលកម្ម និងពលករកម្ពុជាទាំងអស់ តាមរយៈការដាក់ចេញនូវវិធានការនានា ដែលលើកទឹកចិត្តដល់ការវិនិយោគក្នុងស្រុក និង ដែលទាក់ទាញវិនិយោគផ្ទាល់ពីបរទេស នៅតាមបណ្តាវិស័យជាអាទិភាពទាំងឡាយ ពិសេសវិស័យកសិកម្ម កសិ-ឧស្សាហកម្ម ឧស្សាហកម្ម អតិពលកម្ម និងទេសចរណ៍ និង ការបង្កើតបណ្តាញបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈជូនជនក្រីក្រ ដែលផ្សារភ្ជាប់ជាមួយនឹងមជ្ឈមណ្ឌលសំរាប់ជួយរកការងារធ្វើឱ្យយុវជន ជាពិសេសយុវជនដែលទើបចេញពីសាលាឱ្យបានស្របតាមតម្រូវការនៃទីផ្សារពលកម្ម ព្រមទាំងការរៀបចំប្រព័ន្ធស្ថិតិការងារជាដើម ។ ការយកចិត្តទុកដាក់ក៏នឹងត្រូវបានផ្តោតជាពិសេសផងដែរ ទៅលើការពង្រឹងការគ្រប់គ្រងពលករបរទេសនៅកម្ពុជា ក្នុងទិសដៅដោះស្រាយការងារធ្វើជូនប្រជាពលរដ្ឋផង និង ស្រូបយកបច្ចេកវិទ្យាថ្មីសំរាប់ការអភិវឌ្ឍន៍ប្រទេសជាតិផង ។

គោលនយោបាយការងារ និងការបណ្តុះបណ្តាល រួមមាន ការផ្តល់ឱកាសផ្លាស់ប្តូរទីកន្លែងជំនាញថ្មី ដូចជា បច្ចេកវិទ្យាពត៌មាន និង ការបណ្តុះបណ្តាលវិជ្ជាជីវៈ។ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវផ្សារភ្ជាប់ទៅនឹងគោល-នយោបាយអប់រំឱ្យបានប្រកបដោយប្រសិទ្ធភាព ។ ការនាំចេញពលកម្ម គឺជាជម្រើសមួយដ៏សំខាន់ សំរាប់កាត់បន្ថយភាពក្រីក្រក្នុងបណ្តាប្រទេសជិតខាងកម្ពុជានៅទ្វីបអាស៊ី ។ គោលនយោបាយរបស់រាជរដ្ឋាភិបាល គឺលើកទឹកចិត្តការនាំចេញពលកម្មជាផ្លូវការ ដើម្បីបង្កើនសុខុមាលភាព និង ធ្វើឱ្យ

ប្រសើរឡើងនូវជំនាញ កាត់បន្ថយភាពគ្មានការងារធ្វើ និង បង្កើនប្រាក់ចំណូលរបស់ប្រជាពលរដ្ឋ ។

ការវិនិយោគក្នុងទីក្រុង គឺជាគោលនយោបាយដ៏សំខាន់ក្នុងការគាំពារដល់ជនក្រីក្រ ប្រសិនបើវិនិយោគនេះ បង្កើតការងារផលិតកម្ម ដើម្បីស្រូបយកចំនួនពលករដ៏ច្រើនលើសលប់ ដែលមកពីទីជនបទ ។ ការរីកលូតលាស់នៃឧស្សាហកម្មអតិពលកម្ម ដូចជា ឧស្សាហកម្មកាត់ដេរជាដើម បានបង្កើតជាគ្រឹះដ៏រឹងមាំមួយ ក្នុងការបង្កើនប្រាក់ចំណូលពិតប្រាកដសំរាប់ប្រជាជនម្នាក់ៗ និង ដើម្បីសម្រេចបាននូវការកាត់បន្ថយភាពក្រីក្រ ។ ទន្ទឹមនឹងនោះ ការអភិវឌ្ឍន៍កម្មន្តសាលអតិពលកម្ម បានស្រូបយកកម្លាំងពលកម្មពីទីជនបទ ហើយអាចបង្កើនប្រាក់ចំណូល ដែលជាកត្តាមួយជួយកាត់បន្ថយភាពក្រីក្រពីដើមទីតែម្ដង ។

រាជរដ្ឋាភិបាលបាន និង កំពុងដាក់ចេញនូវកម្មវិធី ដើម្បីបង្កើនផលិតភាពកសិកម្ម ដែលជាគន្លឹះមួយនាំឱ្យមានកំណើនសេដ្ឋកិច្ច ។ កម្មវិធីនេះ មានគោលដៅបង្កើនបរិមាណកសិផល ប្រាក់ចំណូល និង លើកដម្កើងកំរិតជីវភាព ព្រមទាំងបង្កើតការងារ តាមរយៈការធ្វើប្រពលវប្បកម្មប្រព័ន្ធដាំដុះ និងបង្កើនការដាំដុះដំណាំច្រើនមុខ ដែលប្រសើរជាងការប្រើប្រាស់ម៉ាស៊ីន ដែលនឹងធ្វើឱ្យកសិករបាត់បង់ការងារធ្វើ ហើយត្រូវទៅរកការងារធ្វើនៅក្នុងវិស័យផ្សេងវិញ ។ យុទ្ធសាស្ត្រពន្លឿនកំណើនកសិកម្មរបៀបនេះនឹងមានផលល្អផ្ទួនៗគ្នា ដោយបង្កើនកាលានុវត្តភាពការងារនៅក្នុងវិស័យផ្សេងៗទៀត តាមរយៈកំណើនតម្រូវការទំនិញ និងសេវា នៅក្នុងវិស័យទាំងនោះ ។

### *មុំទី៤. ការរៀបចំប្រព័ន្ធសុវត្ថិភាពសង្គម សំរាប់មន្ត្រី បុគ្គលិក កម្មករ :*

រាជរដ្ឋាភិបាលនឹងបង្កើនអន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច ដោយពង្រឹងកិច្ចសហប្រតិបត្តិការជាមួយនឹងអង្គការជាតិ និង អន្តរជាតិនានា នៅក្នុងទិសដៅលើកស្ទួយកាលានុវត្តភាពការងារ កាត់បន្ថយភាពងាយរងគ្រោះរបស់ប្រជាជនក្រីក្រ បង្កើនសកម្មភាពសង្គ្រោះបន្ទាន់ ដើម្បីជួយដល់អ្នករងគ្រោះដោយគ្រោះធម្មជាតិ និងគ្រោះមហន្តរាយផ្សេងៗ និងពង្រីកកម្មវិធីស្តារលទ្ធភាពពលកម្មសំរាប់ជនពិការ ព្រមទាំងកម្មវិធីលើកកំពស់សុខុមាលភាពរបស់ជនចាស់ជរា កុមារកំព្រា ស្ត្រីរងគ្រោះ ជនអនាថាដែលគ្មានទីពឹង អតីតយុទ្ធជន និង គ្រួសារ ។

រាជរដ្ឋាភិបាលបន្តជួយឧបត្ថម្ភឱ្យបានជិតដល់ចំពោះជនពិការ និង គ្រួសារយុទ្ធជន ដែលបានបូជាជីវិតដើម្បីប្រទេសជាតិ ព្រមទាំងជម្រុញឱ្យម្ចាស់សហគ្រាស រោងចក្រ ឧបត្ថម្ភប្រាក់បៀវត្ស រួមជាមួយកម្រែបេឡាសន្តិសុខសង្គម ដល់កម្មករជាជំហានៗ ឱ្យបានសមស្របតាមកំរិតលក្ខខណ្ឌទីផ្សារការងារ ។

រាជរដ្ឋាភិបាលនឹងពង្រឹងយ៉ាងហ្មឹងម៉ាត់ នូវការអនុវត្តន៍ច្បាប់ការងារ និង អនុសញ្ញាអន្តរជាតិនានាស្តីពីតួនាទីសហជីព ដើម្បីធានាយ៉ាងពិតប្រាកដនូវសិទ្ធិ និង ផលប្រយោជន៍កម្មករ និយោជិត និង និយោជក ។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលនឹងបន្តអាទិភាពពិសេសលើការកែលំអឱ្យ

កាន់តែប្រសើរឡើង នូវលក្ខខណ្ឌការងាររបស់កម្មករ និង និយោជិត ការ-ជម្រុញអនុវត្តច្បាប់ស្ដីពីរបបសន្តិសុខសង្គម ការអនុវត្តន៍គោលការណ៍ផ្ដល់របបសោធននិវត្តន៍ សោធនសម្រាប់អ្នកបាត់បង់សមត្ថភាពពលកម្ម និងអ្នកនៅក្នុងបន្ទុក និង ការធានាគាំពារចំពោះគ្រោះថ្នាក់ការងារសំរាប់ជនទាំងឡាយដែលស្ថិតក្រោមបទបញ្ញត្តិនៃច្បាប់ការងារ ។

## ចតុកោណទី ៤. ការកសាងសមត្ថភាព និង ការអភិវឌ្ឍន៍ធនធានមនុស្ស

### *មុំទី១. ការពង្រឹងគុណភាពវិស័យអប់រំ*

រាជរដ្ឋាភិបាល បានដាក់ចេញនូវយុទ្ធសាស្ត្រដ៏ទូលំទូលាយមួយសំរាប់វិស័យអប់រំ ដែលមានចែងលំអិតក្នុងផែនការយុទ្ធសាស្ត្រសំរាប់ទ្រទ្រង់វិស័យអប់រំ (ESSP) សំរាប់ឆ្នាំ ២០០១-២០០៥ ។

គោលដៅសំខាន់នៃយុទ្ធសាស្ត្រនេះ គឺការលើកស្ទួយសមត្ថភាពធនធានមនុស្សឱ្យមានមុខជំនាញ បច្ចេកទេស និងវិទ្យាសាស្ត្រខ្ពង់ខ្ពស់ដែលអាចឆ្លើយតបប្រកបដោយប្រសិទ្ធភាព ទៅនឹងតម្រូវការនៃទីផ្សារពលកម្ម មានស្មារតីសហគ្រិនភាព និង គំនិតច្នៃប្រឌិតខ្ពស់ មានស្មារតីទទួលខុសត្រូវ មានវិន័យ សីលធម៌ និង គុណធម៌ល្អប្រសើរ មានមនសិការការងារ និងអត្តចរិតស្លូតត្រង់ ដើម្បីលើកស្ទួយការអភិវឌ្ឍន៍ប្រទេសជាតិ ។

រាជរដ្ឋាភិបាលបន្តប្រឹងប្រែងសម្រេចទិសដៅ ***«អប់រំសំរាប់ទាំងអស់គ្នា»*** តាមរយៈការធានាសមធម៌ក្នុងការអប់រំមូលដ្ឋានរយៈពេល ៩ ឆ្នាំសំរាប់កុមារគ្រប់រូប និង ការបង្កលក្ខណសម្បត្តិអនុគ្រោះនានា ដើម្បីឱ្យកូន

ចៅប្រជាពលរដ្ឋក្រីក្រ មានលទ្ធភាពចូលសិក្សា ជាពិសេសគឺតាមរយៈការ-ពង្រីង និងពង្រីកគ្រឹះស្ថានសិក្សាសាធារណៈ និង ការបង្កើនអាហារូបករណ៍សំរាប់សិស្ស និងនិស្សិតក្រីក្រ ។ រាជរដ្ឋាភិបាលនឹងបន្តពង្រឹងភាពជាដៃគូជាមួយវិស័យឯកជន ព្រមទាំងសហគមន៍ជាតិ និង អន្តរជាតិ ដើម្បីបង្កើន និង លើកកំពស់គុណភាពសេវាអប់រំ ទាំងក្នុងកំរិតមធ្យមសិក្សា បណ្តុះ-បណ្តាលវិជ្ជាជីវៈ និង បច្ចេកទេស ទាំងក្នុងកំរិតឧត្តមសិក្សា ឱ្យឆ្លើយតបបាន យ៉ាងសមស្របទៅនឹងស្តង់ដារអន្តរជាតិ និង តម្រូវការអភិវឌ្ឍន៍របស់ប្រទេស ។

រាជរដ្ឋាភិបាលនឹងបន្តខិតខំបង្កើនចំណាយថវិកា និងកៀងគរជំនួយបរទេសឱ្យបានច្រើនថែមទៀត សំរាប់លើកទឹកចិត្តគ្រូបង្រៀន ធានាគុណ-ភាពបណ្តុះបណ្តាល បង្កើនការផ្គត់ផ្គង់សំភារៈសិក្សា បណ្ណាល័យ និង មន្ទីរពិសោធន៍ បង្កើតអន្តេវាសិកដ្ឋានសំរាប់សិស្ស-និស្សិត ពិសេសសំរាប់សិស្ស-និស្សិតជានារីភេទ បន្តជម្រុញកំណែទម្រង់កម្មវិធីសិក្សា ផ្តល់អា-ហារូបករណ៍ដល់សិស្ស និង និស្សិតក្រីក្រ ផ្តល់ថវិកាសំរាប់កសាងសាលារៀននៅតាមជនបទ និងសំរាប់ដំណើរការគ្រឹះស្ថានសិក្សាផ្សេងទៀត ព្រម-ទាំងសំរាប់ជម្រុញកម្មវិធីអក្ខរកម្ម និង ការអប់រំក្រៅប្រព័ន្ធ ។

***មុំទី២. ការលើកកំពស់សេវាសុខាភិបាលៈ***

ដូចដែលបានគូសបញ្ជាក់ នៅក្នុងផែនការយុទ្ធសាស្ត្រវិស័យសុខា-ភិបាលបើកទូលាយសំរាប់ឆ្នាំ ២០០៣-២០០៧ រាជរដ្ឋាភិបាលនឹងបង្កើនការប្រើប្រាស់ធនធានសាធារណៈ និងជំនួយអន្តរជាតិ ព្រមទាំងបន្តលើកទឹកចិត្តដល់ផ្នែកឯកជន ដើម្បីបង្កើនការវិនិយោគក្នុងវិស័យសុខាភិបាល សំដៅ

លើកកំពស់សុខភាពរបស់ប្រជាពលរដ្ឋ ។ អាទិភាព នឹងត្រូវបានបន្តផ្តល់ទៅលើការកសាងមន្ទីរពេទ្យបង្អែក និង មណ្ឌលសុខភាព នៅទូទាំងប្រទេស ដែលអាចផ្តត់ផ្គង់សេវាសុខាភិបាលមូលដ្ឋាន ប្រកបដោយប្រសិទ្ធភាព សមធម៌ និងនិរន្តរភាព ជូនដល់ប្រជាពលរដ្ឋគ្រប់រូប ជាពិសេស ជនក្រីក្រ និង ក្រុមជនងាយរងគ្រោះ ។ រាជរដ្ឋាភិបាលនឹងបន្តផ្តោតការយកចិត្តទុកដាក់លើការអនុវត្តន៍កម្មវិធីបង្ការ និងព្យាបាលជម្ងឺឆ្លងនានា ការគាំពារមាតា និង ទារក ដើម្បីកាត់បន្ថយអត្រាមរណភាពមាតា និង ទារក ការសង្គ្រោះបន្ទាន់ ព្រមទាំងការអប់រំ និង ផ្សព្វផ្សាយពត៌មានសុខាភិបាល និង អនាម័យឱ្យបានទូលំទូលាយ ជាពិសេសដល់ជនបទ ។ ប្រជាពលរដ្ឋក្រីក្រត្រូវទទួលបាននូវការពិនិត្យពេតដោយឥតគិតថ្លៃនៅតាមមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព ។ មូលនិធិសមធម៌ ដែលត្រូវបានរចនារៀបចំឡើងសំរាប់ជួយជនក្រីក្រឱ្យបានទទួលសេវាសុខភាពប្រកបដោយគុណភាព នឹងត្រូវបានបន្តជម្រុញពង្រឹង និង ពង្រីកថែមទៀត ។ រាជរដ្ឋាភិបាលប្តូរផ្តាច់ជម្រុញការរៀបចំ និង អនុវត្តច្បាប់ និង បទបញ្ញត្តិនានាពាក់ព័ន្ធនឹងវិស័យសុខាភិបាលឱ្យមានប្រសិទ្ធភាព ដើម្បីធានាស្តង់ដារគុណភាពខ្ពស់មួយ ក្នុងការផ្គត់ផ្គង់សេវាសុខភាព និងឱសថ និង ក្នុងការធានាសុវត្ថិភាពចំណីអាហារ ។ រាជរដ្ឋាភិបាល នឹងបន្តអនុវត្តគោលនយោបាយលើកទឹកចិត្តការប្រើប្រាស់ឱសថបូរាណតួបផ្សំនឹងឱសថសម័យ ដោយមានការផ្តល់ពត៌មាន និង ការត្រួតពិនិត្យត្រឹមត្រូវ ។

***មុំទី៣. ការអនុវត្តន៍គោលនយោបាយយេនឌ័*** *(Gender Policy):*

ស្ត្រី គឺជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និងសង្គមជាតិយើង ។ រាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងដើម្បីជួយលើកស្ទួយឋានៈរបស់ស្ត្រី តាមរយៈការបន្តអនុវត្តនូវផែនការយុទ្ធសាស្ត្រ ***«នារីរតនៈ»*** ឬ ស្ត្រីគឺជាត្បូងមានតម្លៃ ក្នុងគោលបំណងផ្តល់ជូនស្ត្រីខ្មែរនូវតម្លៃ និង ក្តីសង្ឃឹមក្នុងជីវិត និង ផ្ដោតលើបញ្ហាយេនឌ័ (Gender Mainstreaming) ក្នុងដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ។ គោលបំណងចំបងនៃកម្មវិធីនេះ គឺការកសាងសមត្ថភាពរបស់ស្ត្រី និង ការកែប្រែអកប្បកិរិយាក្នុងសង្គម ដែលមានការរើសអើងចំពោះស្ត្រី ។

រាជរដ្ឋាភិបាលផ្តល់អាទិភាពខ្ពស់ទៅការលើកកំពស់តួនាទី និងស្ថានភាពសង្គមរបស់ស្ត្រីកម្ពុជា ដោយយកចិត្តទុកដាក់ជម្រុញការអនុវត្តន៍យុទ្ធសាស្ត្រយេនឌ័ (Gender Strategy) ការកសាងសមត្ថភាពស្ត្រីលើគ្រប់ផ្នែក ការកែប្រែឥរិយាបថក្នុងសង្គម ដែលមានការរើសអើងចំពោះស្ត្រីភេទ និង ការធានាសិទ្ធិ ដើម្បីឱ្យស្ត្រីភេទមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការចូលរួមយ៉ាងសកម្ម និង ដោយស្មើភាពក្នុងដំណើការកសាងប្រទេស ។ ក្នុងន័យនេះ ស្ត្រីគ្រប់រូបមានសិទ្ធិក្នុងការទទួលបានការថែទាំសុខភាព ការសិក្សា និង ការបណ្តុះបណ្តាលមុខជំនាញនៅគ្រប់កំរិត ការទទួលបានធនធានសេដ្ឋកិច្ចដោយសមធម៌ ឱកាសចូលរួមប្រាស្រ័យដោយស្មើភាពក្នុងកិច្ចការអភិវឌ្ឍន៍សេដ្ឋកិច្ច- សង្គមកិច្ច ក៏ដូចជាការទទួលបានការការពារតាមផ្លូវច្បាប់ប្រកបដោយយុត្តិធម៌ ដើម្បីធានាសមភាពរវាងបុរស និងស្ត្រី និង ការជួយស្ត្រីឱ្យរួចផុតពីអំពើហឹង្សាក្នុងគ្រួសារ និងពីការជួញដូរផ្លូវភេទ ។ ចំណែកដីសំខាន់

មួយទៀតក្នុងកិច្ចការនេះ គឺការយកចិត្តទុកដាក់បង្កើនសមាមាត្រនៃការចូលរួមរបស់ស្ត្រីឱ្យបានជាអតិបរមា តាមតែអាចធ្វើទៅបាន ក្នុងស្ថាប័នជាតិគ្រប់ថ្នាក់ តាំងពីថ្នាក់កណ្ដាល រហូតដល់ថ្នាក់មូលដ្ឋាន ។

*មុំទី៤. ការអនុវត្តន៍គោលនយោបាយប្រជាជន:*

ជាធម្មតាប្រជាជនកម្ពុជាកើនឡើងប្រមាណ ២,៤% ក្នុងមួយឆ្នាំ ។ នេះ គឺជាបន្ទុកដ៏ធ្ងន់សំរាប់វិស័យផលិតកម្ម និងការបង្កើតពលកម្មដែលនៅមានកំណើនយឺតពុំទាន់សមស្របទៅតាមតម្រូវការជាក់ស្ដែងនៅឡើយ ។ រាជរដ្ឋាភិបាលទទួលស្គាល់ថា កំណើនប្រជាជនខ្ពស់មានផលប៉ះពាល់ជាអវិជ្ជមានទៅលើភាពក្រីក្រ តាមរយៈ ការបង្កើនចំនួនបន្ទុកទៅលើអ្នកដែលមានប្រាក់ចំណូលនៅក្នុងគ្រួសារ ការបង្កើនចំនួនការងារមិនពេញលេញ និង ភាពគ្មានការងារធ្វើ និង ការធ្វើឱ្យធ្លាក់ចុះនូវប្រាក់កម្រៃការងារ ប្រសិនបើកម្លាំងពលកម្មមិនត្រូវបានស្រូបទាញបានច្រើន ដោយវិស័យសេដ្ឋកិច្ចនោះទេ ។ ម្យ៉ាងទៀត កំណើនប្រជាជនខ្ពស់ពេកនឹងមានផលប៉ះពាល់ទៅលើលទ្ធផលនៃការអប់រំ ដោយបង្កើនសម្ពាធទៅលើការផ្ដល់សេវាសាធារណៈ ក្នុងវិស័យនេះ ។ លើសពីនេះទៀត ជាទូទៅ កំណើនប្រជាជនខ្ពស់ គឺជាប្រការឆ្លុះបញ្ចាំងឱ្យឃើញអំពីវិសមភាពផ្នែកភេទ ដោយសារថា ស្ត្រីគ្មានជម្រើសខាងបន្តពូជ ហើយទទួលរងនូវគម្នាបនៃទំនៀមទំលាប់ប្រពៃណីហួសសម័យអំពីបញ្ហាផ្លូវភេទរបស់ស្ត្រី ។ ក្នុងន័យនេះ មរណភាពទារក និងកុមារមានការពាក់ព័ន្ធយ៉ាងជិតស្និទ្ធជាមួយនឹងការពន្យារកំណើត និង អាយុរបស់មាតានៅពេលសម្រាលកូន ។ នៅក្នុងទិដ្ឋភាពផ្សេងទៀត កំណើនយ៉ាងលឿននៃប្រជាជននៅទីជនបទ គឺជាចំណែកនៃការកើនឡើងនូវការ-

កាប់បំផ្លាញព្រៃឈើ ការរិចរិលដី ការហិនហោចធនធានទឹក និង ការថយចុះនូវធនធានជីវសាស្ត្រចម្រុះ ។ ចំណែកនៅទីក្រុង ប្រការនេះ នាំឱ្យមានសម្ពាធទៅលើការផ្គត់ផ្គង់ទឹក និង អនាម័យ ហើយក៏មានផលប៉ះពាល់អវិជ្ជមានផងដែរ ទៅលើខ្យល់ដកដង្ហើម ។ ជាងនេះទៅទៀត កំណើនប្រជាជនខ្ពស់ ជារឿយៗ តែងពាក់ព័ន្ធ ទៅនឹងជម្លោះដែលមានចំនួនកាន់តែច្រើនឡើងៗ អំពីដីធ្លីនៅតាមជនបទ ហើយក៏ជាកត្តាចូលរួមបង្កជម្ងឺសង្គមក្នុងទីក្រុងផងដែរ ដូចជា ការរស់នៅកកកុញ ការរាលដាលនៃជម្ងឺឆ្លង និង ការប្រព្រឹត្តិបទល្មើសផ្សេងៗ ។

បើនិយាយជារួម កំណើនប្រជាជនខ្ពស់ បង្កើននូវសម្ពាធទៅលើតម្រូវការសេវាសាធារណៈ ដែលជាបន្ទុកទៅលើហិរញ្ញវត្ថុរបស់រដ្ឋាភិបាល ហើយថែមទាំងបង្កើតឥទ្ធិពលអវិជ្ជមាន ទៅលើការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និង សង្គមកិច្ចផងដែរ ។

មើលឃើញយ៉ាងនេះ រាជរដ្ឋាភិបាល នឹងបន្តជម្រុញអនុវត្តយ៉ាងសកម្មនូវគោលនយោបាយប្រជាជន ស្របទៅតាមបរិការណ៍សង្គម និង វប្បធម៌កម្ពុជា ដែលសំដៅជាសំខាន់ទៅលើអាទិភាពមួយចំនួនដូចតទៅ :

- គាំទ្រដល់គូស្វាមីភរិយា និងគ្រួសារនីមួយៗ ឱ្យធ្វើការសម្រេចចិត្តដោយសេរី និង ដោយទទួលខុសត្រូវ លើចំនួនកូន និង ការពន្យារកំណើត ព្រមទាំងធានាការផ្ដល់ពត៌មាន ការអប់រំ ការផ្ដល់សេវាកម្ម និង មធ្យោបាយពាក់ព័ន្ធផ្សេងៗ ដើម្បីអនុវត្តការសម្រេចចិត្តខាងលើ ។

- កាត់បន្ថយអត្រាខ្ពស់នៃលទ្ធភាពផ្ដល់កំណើត និង បង្កើនការប្រើប្រាស់សេវាពន្យារកំណើត ។

- កាត់បន្ថយអត្រានៃ «ភាពមានជម្ងឺ» ដែលធ្វើឱ្យស្លាប់ និង អត្រាមរណភាពរបស់ទារក កុមារ និង ម្តាយ ។

- ជម្រុញឱ្យមានសមភាព និង សមធម៌យេនឌ័រ និង លើកកំពស់ការអភិវឌ្ឍន៍ធនធានមនុស្ស ។

- កាត់បន្ថយផលប៉ះពាល់នៃសម្ពាធប្រជាជន ទៅលើបរិស្ថាន និង ធនធានធម្មជាតិ ។

- ពង្រឹងបន្ថែមទៀត នូវការទប់ស្កាត់ការរីករាលដាលមេរោគហ៊ីវ/អេដស៍ ។ និង

- បញ្ចូលអញ្ញត្តិប្រជាជន ទៅក្នុងសមីការនៃគោលនយោបាយសេដ្ឋកិច្ច- សង្គមកិច្ច និង ទៅក្នុងផែនការ និង កម្មវិធីនានា នៅគ្រប់កំរិតទាំងអស់ ។

សរុបសេចក្តីមក ការអនុវត្តន៍ប្រកបដោយប្រសិទ្ធភាពនូវគោល-នយោបាយប្រជាជននេះ ពិតជាមានសារសំខាន់ខ្លាំងណាស់ សំរាប់ការកាត់បន្ថយនូវភាពក្រីក្ររបស់ប្រជាជន ជាពិសេស គឺការសម្រេចឱ្យបានទៅតាមគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (MDGs) ដែលកំណត់ឱ្យប្រទេសនីមួយៗ កាត់បន្ថយភាពក្រីក្រឱ្យបានពាក់កណ្តាលនៅឆ្នាំ ២០១៥ ខាងមុខ ។

## សេចក្តីសន្និដ្ឋាន

ឆឆឆ✿ឆឆ

កម្ពុជាបានចំណាយពេលវេលា និង បានខិតខំប្រឹងប្រែងយ៉ាងពេញទំហឹងអស់រយៈពេលរាប់ទសវត្សរ៍ ដើម្បីស្តារ និង កសាងប្រទេសឡើងវិញពី

ការបំផ្លិចបំផ្លាញនៃរបបប្រល័យពូជសាសន៍ និងសង្គ្រាមរ៉ាំរ៉ៃ ទម្រាំសម្រេចបាននូវសុខសន្តិភាពពេញលេញ ស្ថិរភាពនយោបាយ សណ្តាប់ធ្នាប់សង្គម លទ្ធិប្រជាធិបតេយ្យ ការគោរពសិទ្ធិមនុស្ស និងស្ថិរភាពសេដ្ឋកិច្ចរឹងមាំដែលត្រូវបានសាធារណៈមតិជាតិ និង អន្តរជាតិកោតសរសើរ និងទទួលស្គាល់ ។ កន្លងមក យើងបានអនុវត្តកម្មវិធីកំណែទម្រង់គ្រប់វិស័យ ដោយបានឆ្លងកាត់ការលំបាក និង ឧបសគ្គជាតូចច្រើនរាប់មិនអស់ ចាប់តាំងពីពាក់កណ្តាលទសវត្សរ៍ឆ្នាំទី ៨០ ដើម្បីឆ្លងអន្តរកាលពីសេដ្ឋកិច្ចបែបផែនការ មកបង្កើតបាននូវប្រព័ន្ធសេដ្ឋកិច្ចទីផ្សារដ៏រស់រវើក ព្រមទាំងបង្កើតបានលក្ខខណ្ឌល្អប្រសើរសំរាប់កម្ពុជាសមាហរណកម្មខ្លួនយ៉ាងឆាប់រហ័ស ទៅក្នុងរចនាសម្ព័ន្ធសេដ្ឋកិច្ចតំបន់ និង ពិភពលោក ។

សំរាប់រយៈពេលវែងខាងមុខ ភាពប្រឈមចំបងបំផុតចំពោះកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ដើម្បីអភិវឌ្ឍន៍ គឺការកាត់បន្ថយនូវភាពក្រីក្រ និង ការធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា ដែលកំពុងតែមានកំណើនយ៉ាងលឿន ។ រាជរដ្ឋាភិបាលយល់ច្បាស់ និង បានចាត់ទុកភាពក្រីក្រថា ជាការខាតបង់ខាងសេដ្ឋកិច្ចដ៏ធ្ងន់ធ្ងរ និងជាការដែលមិនអាចទទួលយកបានខាងសីលធម៌ ដែលអាចនាំទៅដល់ភាពបែកបាក់នៃសង្គមជាតិ ។ គឺនៅលើមូលដ្ឋាននៃទស្សនវិជ្ជានេះហើយ ដែលយើងបានដាក់ចេញនូវយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ដែលមានគោលដៅគន្លឹះចំបងៗដូចខាងក្រោម ÷

ទី១- ពង្រឹងសន្តិភាព សន្តិសុខ ស្ថិរភាព និង សណ្តាប់ធ្នាប់សង្គមតាមរយៈវិធានការជាក់ស្តែងនានា សំដៅលើកស្ទួយនីតិរដ្ឋ ការពារសិទ្ធិ

មនុស្ស និង លទ្ធិប្រជាធិបតេយ្យ ដើម្បីបង្កើតឡើងនូវបរិស្ថាននយោបាយ និង សន្តិសុខ ដែលអនុគ្រោះសំរាប់ការអភិវឌ្ឍន៍ប្រកបដោយចិរភាព នៅក្នុងរយៈពេលវែង ។

ទី២- ធានាឱ្យបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចិរភាព ក្នុងរយៈពេលវែង ក្នុងអត្រាខ្ពស់ ពី ៦ ទៅ ៧% ក្នុងមួយឆ្នាំ ។

ទី៣- បែងចែកផ្លែផ្កានៃកំណើនសេដ្ឋកិច្ច ប្រកបដោយសមធម៌ រវាងអ្នកមាន និងអ្នកគ្មាន រវាងទីក្រុង និងជនបទ និងរវាងស្ត្រី និងបុរស ។

ទី៤- ធានាគ្រប់គ្រង និង ប្រើប្រាស់ប្រកបដោយចិរភាព និង និរន្តរភាពនូវបរិស្ថាន និង ធនធានធម្មជាតិ ។

តាមរចនាសម្ព័ន្ធ ដែលបានអធិប្បាយនៅខាងលើនេះ ***«យុទ្ធសាស្ត្រចតុកោណ»*** នឹងបន្តពី ***«យុទ្ធសាស្ត្រត្រីកោណ»*** ក្នុងការពង្រឹង និងអភិវឌ្ឍន៍សមិទ្ធផលទាំងឡាយរបស់រាជរដ្ឋាភិបាលនីតិកាលទី ២ នៃរដ្ឋសភា ។ ម្យ៉ាងទៀត ***«យុទ្ធសាស្ត្រចតុកោណ»*** នេះ គឺជា **របៀបវារៈគោលនយោបាយសេដ្ឋកិច្ច** នៃ ***«កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលសំរាប់នីតិកាលទី ៣ នៃរដ្ឋសភា»*** ដែលត្រូវបានរៀបចំឡើងជាប្រព័ន្ធមួយ មានលក្ខណៈគ្រប់ជ្រុងជ្រោយ ស៊ីសង្វាក់ ប្រទាក់ក្រឡាគ្នា និង យោងគ្នាទៅវិញទៅមក ហើយងាយយល់ និង ងាយគ្រប់គ្រង ។ ក្នុងន័យនេះ ***«យុទ្ធសាស្ត្រចតុកោណ»*** គឺជាឧបករណ៍គោលនយោបាយ ប្រកបដោយប្រសិទ្ធភាពរបស់រាជរដ្ឋាភិបាលនីតិកាលទី ៣ នៃរដ្ឋសភា សំរាប់បន្តជម្រុញអនុវត្តនូវ ***«យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ»*** ដែលមានគោលដៅគន្លឹះចំបងទាំងបួន ដូចបានគូសបញ្ជាក់ខាងលើ ។

រាជរដ្ឋាភិបាលទទួលស្គាល់ថា កម្ពុជានៅមានផ្លូវដ៏វែងអន្លាយសំរាប់ធ្វើដំណើរទៅមុខ ហើយត្រូវពុះពារឆ្លងកាត់ឧបសគ្គរាប់មិនអស់ ថែមទៀត ដើម្បីសម្រេចបាននូវវឌ្ឍនភាព និង វិបុលភាពដ៏រុងរឿងថ្កើងថ្កានជូនប្រទេសជាតិ និង ប្រជាជន ។ ក្នុងន័យនេះ ការខិតខំដើម្បីកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន នៅតែជាគោលដៅដ៏ចំបងបំផុតរបស់រាជរដ្ឋាភិបាលនៃរដ្ឋសភានីតិកាលទី ៣ នេះ ។ ពិតណាស់ រាជរដ្ឋាភិបាលទទួលស្គាល់ថា គ្រប់បញ្ហានៃភាពក្រីក្រ ពុំអាចនឹងត្រូវបានដោះស្រាយរួចស្រេចបាច់អស់ក្នុងរយៈពេលតែមួយថ្ងៃ ឬ មួយខែ ឬ មួយឆ្នាំនោះឡើយ ។ ក៏ប៉ុន្តែ ដោយមានកម្មវិធីច្បាស់លាស់ និង ដោយមានការខិតខំប្រឹងប្រែងរួមគ្នាយ៉ាងឥតសំចៃ និង ដោយស្មោះត្រង់ យើងប្រាកដជាអាចធ្វើឱ្យមានការផ្លាស់ប្តូរជាវិជ្ជមានយ៉ាងច្រើន នៅក្នុងលើកស្ទួយកំរិតជីវភាពរបស់ប្រជាជនក្នុងរយៈពេល ៤ ឆ្នាំខាងមុខ ។

ក្នុងន័យនេះ រាជរដ្ឋាភិបាល សូមអំពាវនាវដល់គ្រប់ដៃគូអភិវឌ្ឍន៍ទាំងអស់ រួមមាន សហគមន៍អ្នកផ្តល់ជំនួយ វិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល ព្រមទាំងថ្នាក់ដឹកនាំ មន្ត្រីរាជការនៅគ្រប់ក្រសួងស្ថាប័ន ទាំងស្ថាប័ននីតិបញ្ញត្តិ និង នីតិប្រតិបត្តិ ព្រមទាំងតុលាការ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និង ប្រជាពលរដ្ឋគ្រប់រូប សូមផ្តល់ការគាំទ្រគ្រប់បែបយ៉ាង និង សូមយកចិត្តទុកដាក់ចូលរួមឱ្យបានសកម្មជាមួយនឹងរាជរដ្ឋាភិបាល ដើម្បីអនុវត្តឱ្យបានជោគជ័យនូវ ***«កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលសំរាប់នីតិកាលទី ៣ នៃរដ្ឋសភា»*** ពិសេសគឺ ***យុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌***

***និង ប្រសិទ្ធភាព នៅកម្ពុជា*** ដែលជារបៀបវារៈគោលនយោបាយសេដ្ឋកិច្ច នៃកម្មវិធីនយោបាយនេះ ។

***** + *****

*ព្រះអង្គស្តេចក្រុមឃុន ព្រះអង្គម្ចាស់ ព្រះអង្គម្ចាស់ក្សត្រី ឯកឧត្តម លោកជំទាវ--ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ--ដែលជាសមាជិក-សមាជិកានៃអង្គគណៈរដ្ឋមន្ត្រីទាំងមូល!*

ទូលបង្គំ ខ្ញុំ សូមគូសបញ្ជាក់ម្តងហើយម្តងទៀតថា កម្មវិធីកែទម្រង់ទាំងឡាយដែលយើងបានលើកឡើងកន្លងមក និង កំពុងរំលេចឡើងឱ្យកាន់តែច្បាស់ថែមទៀតនាពេលនេះ មិនមែនត្រូវបានដាក់ចេញ ឬ ធ្វើឡើងដើម្បីយកចិត្តអ្នកណាម្នាក់នោះទេ ប៉ុន្តែ វាជាតម្រូវការចាំបាច់របស់កម្ពុជា ហើយដើម្បីបំរើឱ្យផលប្រយោជន៍របស់ប្រជាជនកម្ពុជាទាំងមូល ។ ទូលបង្គំ ខ្ញុំ រំពឹងទុកជាមុនថា ក្រោយពីយើងបែកគ្នាពីអង្គប្រជុំនេះទៅ រាល់បណ្តាគោលនយោបាយ និង វិធានការនានាជាច្រើន ដែលយើងទាំងអស់គ្នាបានដាក់ចេញមក និង បានថ្លែងនៅចំពោះមុខរដ្ឋសភា និងនាពេលនេះ នឹងបានក្លាយទៅជាសកម្មភាពការងារជាក់ស្តែងជាបន្តបន្ទាប់ ដែលវានឹងផ្តល់ផលផ្លែផ្កានៅក្នុងគ្រប់ផ្នែក-គ្រប់វិស័យ ពិសេស វានឹងឆ្លុះបញ្ចាំងឱ្យឃើញយ៉ាងប្រច័ក្ស តាមរយៈការកែលំអ និង ការលើកស្ទួយឡើងជាបណ្តើរៗ នូវកម្រិតជីវភាពរស់នៅរបស់ប្រជាជន ដែលជាខ្នាតយ៉ាងសំខាន់ សំរាប់វាស់ស្ទង់ប្រសិទ្ធភាពនៃការងាររបស់រាជរដ្ឋាភិបាល ។

ជាក់ស្តែង សំរាប់នីតិកាលទី៣ នៃរដ្ឋសភានេះ យើងនៅសល់ពេលតែ ៤ ឆ្នាំទៀតប៉ុណ្ណោះ ដូច្នេះ យើងពិតជាមិនអាចធ្វើដំណើរទៅមុខតាមរបៀបធម្មតាបានទេ ។ យើងទាំងអស់គ្នាច្បាស់ជាត្រូវប្រឹងប្រែងឱ្យអស់ពីសរសៃសស្ទង ដើម្បីជម្រុញល្បឿនអនុវត្តឱ្យបានជោគជ័យនូវកម្មវិធីនយោបាយ យុទ្ធសាស្ត្រ និង វិធានការកែទម្រង់ជាក់ស្តែងទាំងឡាយ ដែលយើងទាំងអស់គ្នាបានដាក់ចេញមកដោយខ្លួនឯង ដើម្បីឧត្តមប្រយោជន៍របស់ប្រទេសជាតិ និង ប្រជាជនកម្ពុជានៃយើង ។ ក្នុងស្មារតីនេះ ទូលបង្គំ ខ្ញុំ សូមស្នើអង្គគណៈរដ្ឋមន្ត្រីរបស់យើងអនុម័តយកថ្ងៃប្រជុំលើកទី ១ របស់ខ្លួននេះ ជាការឧទ្ទិសកម្លាំងកាយ ប្រាជ្ញា និង ស្មារតីរបស់យើងទាំងអស់គ្នាចំពោះការបង្កើនល្បឿននៃកំណែទម្រង់ ដែលមានលក្ខណៈកាន់តែទូលំ-ទូលាយ និង កាន់តែស៊ីជម្រៅឡើង ដើម្បីកាត់បន្ថយនូវភាពក្រីក្ររបស់ប្រជាជន និងដើម្បីវឌ្ឍនភាព វិបុលភាព និង កិត្យានុភាពដ៏ខ្ពស់ត្រដែតនៃព្រះរាជាណាចក្រកម្ពុជា ។

នៅទីបញ្ចប់ ទូលបង្គំ ខ្ញុំ សូមថ្វាយព្រះពរ និង ជូនពរដល់ព្រះអង្គស្តេចក្រុមឃុន ព្រះអង្គម្ចាស់ ព្រះអង្គម្ចាស់ក្សត្រី ឯកឧត្តម លោកជំទាវ ជាសមាជិក- សមាជិកានៃអង្គគណៈរដ្ឋមន្ត្រីទាំងមូល សូមប្រកបដោយព្រះរាជសុខភាព និងសុខភាពល្អបរិបូណ៌ និងសូមសម្រេចបាននូវជោគជ័យដ៏ត្រចះត្រចង់ ក្នុងការបំពេញភារកិច្ចជាមួយគ្នា ក្នុងរយៈពេល ៤ ឆ្នាំ ទៅមុខទៀតនេះ ដើម្បី **ជាតិ សាសនា និង ព្រះមហាក្សត្រ** ដែលជាបាវនាខ្ពស់បំផុតនៃព្រះរាជាណាចក្រកម្ពុជា ។

ទូលបង្គំ ខ្ញុំ សូមប្រកាសបិទអង្គប្រជុំគណៈរដ្ឋមន្ត្រីរបស់យើងនាពេលនេះ ។

*សូមអរព្រះគុណ និង សូមអរគុណ !*